សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

១៩

* ចំណងមិត្តភាពនិងការជួបជុំគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងរួមចិត្ត - សមាគៈ

# ទស្សនាវដ្តី គ្រូបង្រៀន



ខែ មេសា - ឧសភា - មិថុនា ឆ្នាំ ២០០៤
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨ឆ មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | លិខិតជូនពរឆ្នាំថ្មី | ១ |
| ២ | វិចារណកថា | ២ |
| ៣ | សេចក្ដីដកស្រង់ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល | ៣ |
| | **វប្បធម៌ទូទៅ** | |
| ៤ | សិល្បៈវប្បធម៌ខ្មែរ | ៥ |
| ៥ | កំណើតនៃការអប់រំសីលធម៌ | ៩ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | ការអប់រំជាវិទ្យាសាស្ត្រផង និង ជាសិល្បៈផង | ១៤ |
| ៧ | ដំណើរការអភិវឌ្ឍវិស័យអប់រំនៅសហរដ្ឋអាមេរិក | ១៧ |
| | **វិទ្យាសាស្ត្រ និង ព័ត៌មានវិទ្យា** | |
| ៨ | ភាសាដែលគេប្រើប្រាស់ក្នុងអ៊ីនធើណែត | ២៤ |
| ៩ | យកប្រេងកាតធ្វើស្ករ | ២៥ |
| ១០ | រថភ្លើង | ២៦ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ១១ | ល្បិចចងចាំ | ២៩ |
| ១២ | គណិតវិទ្យា : ត្រីកោណ | ៣២ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣៣ |
| ១៤ | ភូមិវិទ្យា : តំបន់អាកាសធាតុ និង ប្រជាជន | ៣៦ |
| | **វាទីកំណាព្យ និង កំសាន្ត** | |
| ១៥ | ច្បាប់ពាក្យចាស់ | ៣៨ |
| ១៦ | ព្រះគុណម៉ែ | ៣៩ |
| ១៧ | នំខ្មែរ | ៤០ |
| ១៨ | ការច្នៃប្រឌិត | ៤១ |
| | **វេទិកាស្ត្រី** | |
| ១៩ | សមាសនាម | ៤២ |
| | **ព័ត៌មាន** | |
| ២០ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេ ? | ៤៤ |
| ២១ | វិញ្ញាសាប្រលងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ | ៤៥ |
| ២២ | វេទិកាស្ត្រី | ៥០ |



**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណារុយ
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី នន់ សុគ្គុំ
- លោក ប៉ែន សារុន
- សមាជិក-សមាជិកា ស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ សិរី
- លោកបណ្ឌិត អ៊ឹម កុច
- លោក ស៊ិន ស៊ឹម
- លោក ស៊ីង វ៉ាន់ថន
- លោក សួង សារុន

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការិកុំព្យូទ័រ**

ក. ម៉ៃ សូនី

**ក្របខាងក្រៅ**

- ពីមុខ: សកម្មភាពអក្ខរកម្មឃុំប្រាជាក
- ពីក្រោយ: ស្ត្រីខ្មែរនៅដើមសតវត្សទី២០

# វិចារណកថា

"ពីតិចទៅច្រើន ពីងាយទៅលំបាក ពីអ្វីដែលធ្លាប់ឃើញទៅអ្វីដែលមិនធ្លាប់ឃើញ" ជាទស្សនាទានដ៏ចំបង ក្នុងការអប់រំខ្លួនក៏ដូចជាអប់រំអ្នកដទៃ ។ ជាក់ស្តែង ពុទ្ធសាសនាបង្រៀនមនុស្សអោយចេះហ្វឹកហាត់អប់រំចិត្តអោយប្រកបដោយមេត្តា ករុណា ដោយអោយប្រព្រឹត្តទៅតាមលំដាប់មាន ៤ យ៉ាងគឺ :

១- ផ្សាយមេត្តាដល់ខ្លួនឯងមុន ដើម្បីដឹងថាខ្លួនឯងមានចិត្តស្រលាញ់សុខ ស្អប់ទុក្ខយ៉ាងណា អ្នកដទៃគេស្រលាញ់សុខ ស្អប់ទុក្ខយ៉ាងនោះដែរ ។

២- លុះហាត់ផ្សាយមេត្តាដល់ខ្លួនឯងហើយ ត្រូវហាត់ផ្សាយមេត្តាដល់បុគ្គលជាទីស្រលាញ់ទាំងឡាយមានមាតាបិតា បុត្រ ភរិយា ស្វាមី រឺបុគ្គល ជាញាតិមិត្តជាបន្តបន្ទាប់ទៅ ។

៣- ក្រោយពីបានផ្សាយមេត្តាដល់បុគ្គលជាទីស្រលាញ់ ជាទីគោរពរាប់អានបានហើយ ត្រូវផ្សាយមេត្តាដល់បុគ្គលពួកកណ្តាល គឺមនុស្សដែលខ្លួនមិនទាន់ស្រលាញ់ មិនទាន់ស្អប់ រឺមិនសូវយកចិត្តទុកដាក់ មិនសូវគិតគូរដល់ ។

៤- ក្នុងទីបំផុត ត្រូវហាត់ផ្សាយមេត្តាដល់មនុស្សដែលធ្លាប់មានពៀរ រឺដែលធ្លាប់ជាសត្រូវនឹងខ្លួន ។ គឺមានតែបុគ្គលប្រភេទទី ៤ ប៉ុណ្ណោះ ដែលមានសេចក្តីលំបាកយ៉ាងខ្លាំងដល់បុគ្គលអ្នកហាត់ផ្សាយមេត្តា ។

លំនាំនេះ អ្នកគ្រូ លោកគ្រូ ធ្លាប់ណែនាំសិស្សជាទូទៅអោយរកឧទាហរណ៍ជាក់ស្តែងក្នុងរឿងផ្ទាល់ខ្លួន ក្នុងគ្រួសារ ក្នុងសាលារៀន ក្នុងសហគមន៍ ក្នុងសង្គម ក្នុងជាតិ អន្តរជាតិ ដើម្បីធ្វើជាឧទ្បីករណ៍ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់ គំនិត ភាសិត ទាំងមតិស្រប ទាំងមតិផ្ទុយ ទាំងមតិសំយោគ ។

ក្នុងកម្មវិធីចងក្រងសៀវភៅសិក្សា ក៏មានលំនាំដូចនោះដែរ ឧទាហរណ៍ : សីលធម៌ ពលរដ្ឋវិជ្ជា ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២ មាន ៥-៦ ជំពូកដូចៗគ្នា គឺជំពូក ទី១ ស្តីពីការ កសាងខ្លួនឯង, ទី២ ពីអន្តរបុគ្គល, ទី៣ ពីសហគមន៍ រឺពីសង្គម, ទី៤ ពីជាតិ, ទី៥ ពីជំនឿសាសនា, ទី៦ ពីទំនាក់ទំនងអន្តរជាតិ ។



# ជូនពរឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំរកាឆស័ក

## ព.ស ២៥៤៨

## គណៈកម្មាធិការនាយក ស.ប.ស.ខ

សូមប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ជូនចំពោះសមាជិក សមាជិកានៃសមាគមបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស សូមប្រកបបានសុខភាពល្អបរិបូណ៌ អាយុយឺនយូរ និង មានពលានុភាពខ្លាំងក្លា ដើម្បីអភិវឌ្ឍការងារអប់រំ និង ការងារសមាគមអោយបានរីកចំរើនរុងរឿងតរៀងទៅ ។

ជ.គណៈកម្មាធិការនាយក

ប្រធាន

យស់ អ៊ាង

# រាជកិច្ច

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៣៤ អនក្រ.បក**

## អនុក្រឹត្យ

### ស្តីពី

### ការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់គាំពារគ្រោះសញ្ញាក្នុងវិស័យអប់រំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែមព្រះរាជក្រឹត្យ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចមានចែងក្នុងជំពូកទី ២ ស្តីពីប្រាក់បំណាច់មុខងារ ។

**មាត្រា ២**

អនុក្រឹត្យនេះ កំណត់ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន និង កំណត់បន្ថែមប្រាក់កំរៃគរុកោសល្យរបស់មន្ត្រីរាជការក្នុងវិស័យអប់រំ ។

## ជំពូកទី ២
## ប្រាក់បំណាច់មុខងារ

**មាត្រា ៣**

មន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាលត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កាំរតទី ៥ | កាំរតទី ៤ | កាំរតទី ៣ | កាំរតទី ២ | កាំរតទី ១ |
|---|---|---|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន | ៦២០ ០០០៛ | ៦៥៨ ០០០៛ | ៦៩៨ ០០០៛ | ៧៤១ ០០០៛ | ៧៨៦ ០០០៛ |
| ២ | អភិបាលរងខេត្ត-ក្រុង | ៦១៥ ០០០៛ | ៦៥៣ ០០០៛ | ៦៩៣ ០០០៛ | ៧៣៦ ០០០៛ | ៧៨១ ០០០៛ |
| ៣ | អធិការថ្នាក់កណ្តាល | ៦១០ ០០០៛ | ៦៤៨ ០០០៛ | ៦៨៨ ០០០៛ | ៧៣១ ០០០៛ | ៧៧៦ ០០០៛ |
| ៤ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៦០៥ ០០០៛ | ៦៤៣ ០០០៛ | ៦៨៣ ០០០៛ | ៧២៦ ០០០៛ | ៧៧១ ០០០៛ |
| ៥ | អភិបាលស្រុក-ខ័ណ្ឌ | ៥០០ ០០០៛ | ៥៣៨ ០០០៛ | ៥៧៨ ០០០៛ | ៦២១ ០០០៛ | ៦៦៦ ០០០៛ |

**មាត្រា ៤**

ប្រធានអង្គភាព ដែលមានរចនាសម្ព័ន្ធក្នុងក្រសួង-ស្ថាប័ន និង ស្មើនាយកដ្ឋាន ត្រូវទទួលបានប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋានដូចមានចែងនៅក្នុងមាត្រា ៣ ។

## ជំពូកទី ៣

## ប្រាក់កំរៃគរុកោសល្យ

**មាត្រា ៥**

ប្រាក់កំរៃគរុកោសល្យ គឺជាប្រាក់បន្ថែមលើប្រាក់បំណាច់មុខងារប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការក្នុងវិស័យអប់រំ ហើយដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យ ។

**មាត្រា ៦**

ប្រាក់កំរៃគរុកោសល្យ ត្រូវផ្តល់ជូនទៅតាមក្របខ័ណ្ឌប្រភេទមន្ត្រីរាជការ ដូចខាងក្រោម :

| ល.រ | ក្របខ័ណ្ឌ | ប្រាក់កំរៃគរុកោសល្យ |
|---|---|---|
| ១ | ប្រភេទ ក | ១២ ០០០៛ |
| ២ | ប្រភេទ ខ | ១០ ០០០៛ |
| ៣ | ប្រភេទ គ | ៨ ០០០៛ |
| ៤ | ប្រភេទ ឃ | ៦ ០០០៛ |

**មាត្រា ៧**

ការកែប្រែប្រាក់កំរៃគរុកោសល្យ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

**មាត្រា ៨**

មន្ត្រីរាជការឯកទេសផ្សេងៗដែលត្រូវបានឧទ្ទេសនាមដោយក្រសួង ស្ថាប័ន អោយបង្ហាត់បង្រៀនពេញពេលនៅតាមគ្រឹះស្ថានសិក្សានានារយៈពេលពេញ ១ឆ្នាំ ត្រូវទទួលបានប្រាក់កំរៃគរុកោសល្យ ។

លិខិតឧទ្ទេសនាម ត្រូវធ្វើឡើង ១ឆ្នាំម្តងៗ ។

## ជំពូកទី ៤

## ប្រាក់បង្គ្រប់

**មាត្រា ៩**

មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សថ្មី (បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់មុខងារ) ទាបជាងប្រាក់បៀវត្សចាស់ ត្រូវទទួលបានប្រាក់បង្គ្រប់ដែលធានាមិនអោយទាបជាងប្រាក់បៀវត្សចាស់ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១០**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

<u>មាត្រា ១១</u>

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

<u>មាត្រា ១២</u>

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**និង ជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ




# សិល្បៈវប្បធម៌ខ្មែរ

**<u>សេចក្ដីផ្ដើមៈ</u>**

ប្រទេសកម្ពុជាសំបូរពោរពេញទៅដោយសម្បត្តិធម្មជាតិយ៉ាងស្រស់ប្រណីត ។ ព្រៃឈើមានតំលៃ ជាជំរកនៃសត្វគ្រប់ប្រភេទគ្របដណ្ដប់លើទឹកដីទាំងមូលបង្កការទាក់ទាញទឹកភ្លៀង កែប្រែធាតុអាកាសអោយមានភាពធម្មតា ព្រមទាំងបំរើគ្រប់តំរូវការសាងសង់លំនៅដ្ឋានយ៉ាងសមរម្យ ។

ផ្នែកម្ហូបអាហារកម្ពុជាមានត្រីទឹកសាប ទឹកប្រៃអាចនេសាទបានរាប់សិបតោនក្នុងមួយឆ្នាំៗ ធានាការហូបចុកក្នុងប្រទេស និង នាំទៅលក់នៅប្រទេសក្រៅទៀតផង ។ តាមតំបន់វាលរាប ដីស្រែចំការរាប់សែនហិកតាលាតសន្ធឹងល្វឹងល្វើយឆ្ងាយសន្លឹម ដែលភាគច្រើនជាដីមានជីជាតិល្អអាចដាំដុះដំណាំគ្រប់ប្រភេទទទួលបានទិន្នផលខ្ពស់ ។ បើនិយាយពីធនធានក្រោមដី ប្រទេសយើងមានរ៉ែមាស ពេជ្រ កែវ ថ្មកំបោរ ដែក សំណ ប្រេងកាត ។ល។ ដែលអាចជាទីសង្ឃឹមក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិអោយរីកចំរើន ។

ជាពិសេសបើនិយាយពីប្រទេសកម្ពុជា គេតែងតែស្ងើចសរសើរដល់ខឿនវប្បធម៌ដ៏រុងរឿងនៃជាតិនេះ ។ បញ្ហានេះកើតឡើងដោយសារអ្វី ?

ទស្សនៈបរទេសមួយចំនួនយល់ថា ភាពរុងរឿងចំរើននៃវប្បធម៌ខ្មែរ អាស្រ័យខ្មែរបានចំលងពីវប្បធម៌ឥណ្ឌា-ចិន ។ គេបានបន្ថែមទៀតថា "ខ្មែរពុំមានសិល្បៈជារបស់ជាតិខ្លួនឯងឡើយ" ។ ចំពោះប្រការនេះ យើងទទួលស្គាល់ថាត្រឹមត្រូវជាបណ្ដោះអាសន្នសិនចុះ ព្រោះខ្មែរ ឥណ្ឌា ចិន ធ្លាប់មានទំនាក់ទំនងគ្នាតាំងពីព្រះមហាក្សត្រខ្មែររៀបអភិសេកជាមួយក្សត្រឥណ្ឌានាសតវត្សទី ១មកម្ល៉េះ ។លុះក្រោយមកទៀត យើងឃើញសំណល់នៃវប្បធម៌ឥណ្ឌាដែលខ្មែរយើងគោរពតាមមានសេសសល់ដល់សព្វថ្ងៃដូចជាព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនាជាដើម ។ក្នុងករណីនេះ យើងសូមបញ្ជាក់អោយខ្លីទៅវិញថា "ថ្វីបើយើងទទួលនូវវប្បធម៌គេមែន ប៉ុន្តែសិល្បករខ្មែរពុំមែនយកវាមកប្រើទាំងដុលនោះទេ" គឺបានសេចក្ដីថាសិល្បករខ្មែរបានកែច្នៃអោយវប្បធម៌នោះទៅជាវប្បធម៌បំរើជីវភាពតាមបែបខ្មែរ មនោសញ្ចេតនាខ្មែរ ឧត្តមគតិខ្មែរសំរាប់អោយខ្មែរទទួលយកមកប្រើប្រាស់កំសាន្តសប្បាយតាមរបៀបខ្មែរ ។ តួយ៉ាងដូចជារឿងរាមាយណៈឥណ្ឌា ដែលអោយតំលៃលើព្រះរាមជាទេវៈដ៏អស្ចារ្យលើលោកយើងនេះ ។ ប៉ុន្តែរឿងរាមកេរ្តិ៍ខ្មែរបែរជាចាត់ទុកព្រះរាមជាមនុស្សធម្មតា ។

ការបញ្ជាក់ភស្តុតាងដ៏ខ្លីមួយនេះ ជាសក្ខីភាពដែលយើងបានឃើញស្រាប់ជាក់ស្តែងនូវប្រាង្គប្រាសាទនានានៅខេត្តសៀមរាបទាំងស្ថាបត្យកម្ម ទាំងខ្លឹមសារ សុទ្ធតែបង្ហាញច្បាស់ពីអត្តចរិត បំណងប្រាថ្នា សញ្ចេតនាស្មារតី ច្បាប់ទំនៀមទំលាប់ របៀបរស់នៅបែបខ្មែរពិតៗ ។

មួយវិញទៀតមានទស្សនៈមួយបានស្រដីថា "ខ្មែរសំបូរកេរដំណែលសិល្បៈច្រើន អាស្រ័យដោយខ្មែរមានភាពទំនេរពីការងារច្រើន"។ កត្តានេះនាំអោយខ្មែរមានគំនិតរវើរវាយ ម៉្លោះហើយដើម្បីកំដរបរិយាកាសអាប់អួរស្ងៀមស្ងាត់ "ខ្មែរបង្កើតសិល្បៈឡើង" ។ តាមពិតមិនដូចនេះទេ : "ខ្មែរជាជាតិមួយដែលមានស្មារតីឧស្សាហ៍ព្យាយាមអំណត់អត់ធន់ ស្រលាញ់ការងារ ចង់បានកិត្តិយសយូរអង្វែង ។ ពិសេសខ្មែរចូលចិត្តអ្វីៗដែលជាសោភ័ណជីវិត និង សន្តិភាព វឌ្ឍនភាព។ ប្រការនេះ ជំរុញអោយខ្មែរបង្កើតនូវសិល្បៈវប្បធម៌ដ៏ឆ្នើមប្រចាំជាតិខ្លួន ដោយពុំរណបសិល្បៈវប្បធម៌បរទេសឡើយ" ។

ជារួម ខ្មែរមានសិល្បៈវប្បធម៌ដោយឡែកសំរាប់ជាតិខ្លួន មានទាំងក្បួនខ្នាត ទំរង់បែបបទជាក់លាក់ដែលកើតចេញពីបញ្ញាញាណផ្ទាល់ខ្លួនដែលយើងខ្ញុំសូមបង្ហាញដូចខាងក្រោមនេះ ÷

❖ **ក្បាច់បាតរបាំប្រពៃណី**

របាំប្រពៃណីមានក្បួនជាច្រើនដែលដកស្រង់ពីក្នុងក្បាច់បាត"ឆាបពុះ"។ ក្បាច់នេះ ជាក្បាច់បាតមូលដ្ឋានធំ ហើយមានសារៈសំខាន់ណាស់ដែលធ្វើអោយសិល្បករបាំនេះ មានបុគ្គលិកលក្ខណៈអាចក្លាយជាសិល្បកររបាំបានល្អនៅលើរបាំនីមួយៗរបស់ខ្លួន ។

សិល្បករខ្មែរនៃរបាំប្រពៃណី បន្ទាប់ពីសិក្សាវិជ្ជាមូលដ្ឋានរួចហើយ ចាំបាច់ត្រូវហ្វឹកហាត់ក្បាច់បាតរបស់របាំប្រពៃណីទៀត ។ ក្បាច់បាតប្រពៃណីខុសគ្នាពីក្បាច់បាតបុរាណបានធ្វើការច្នៃប្រឌិតក្បាច់ ដើម្បីសំរបទៅតាមតំរូវការនៃរបាំនីមួយៗ ។

ជាទូទៅ ក្បាច់បាតប្រពៃណីមានក្បាច់បាតដៃ និង ជើងខុសៗគ្នា។ ក្បាច់បាតប្រពៃណីសំខាន់ៗធ្លាប់ប្រើមាន : រាំវង់ រាំក្បាច់ ចៅខ្វង ភូងាទារី អាឡេ អាល់ភាំផាត់ ភូមា នារីលង្វែក ស៊ីន្ទូន ដើរសេក ឬដើរផ្ចិត ដើរទា ។

- **ក្បាច់រាំវង់ :**

**សំគាល់** : ក្បាច់រាំវង់មានតែមួយបែបទេ កាលណាចាប់ផ្តើមត្រូវធ្វើចលនាដូចតទៅ :

- ដៃមួយនៅលើ ដៃមួយទៀតនៅក្រោម( ដៃឆ្វេងក៏បានដៃស្តាំក៏បាន) ។ ដៃខាងលើ "លា" ដៃខាងក្រោម "ជីប"
- ដៃខាងក្រោមស្ទួយឡើងលើ រួចទំលាក់ចុះក្រោមវិញត្រឹមផ្ចិត
- ការលើកដៃឡើង ឬក៏ដាក់ក្រោមត្រូវគោរពទៅតាមចង្វាក់ភ្លេង ៣-៤ ។ គឺអាចរាំបីចង្វាក់ក៏បានបួនចង្វាក់ក៏បាន
- ពេលរាំជើង និង ដៃត្រូវស្ថិតនៅក្នុងចង្វាក់តែមួយដូចៗគ្នា ។

- **ក្បាច់រាំក្បាច់ :**

ក្បាច់នេះមានចលនារាំដូចតទៅ :

- ដៃមួយនៅលើ ដៃមួយនៅក្រោម ។ ដៃក្រោម "ជីប" ដៃលើ "លា" ។

- ចាប់ផ្តើមរាំ ដៃក្រោមទាញស្នួយទៅលើ ដៃលើទំលាក់ចុះមកក្រោម ។ ដៃទាំងពីរត្រូវគោរពតាមចង្វាក់ភ្លេងជាក់លាក់ ។ មួយចង្វាក់ភ្លេង ដៃទាំងពីរត្រូវឡើង ឬចុះអោយស្របគ្នា ។
- បើដៃណា "ជីប" ជើងស្របនឹងដៃនោះត្រូវបោះជាមួយដៃ ( ដៃស្តាំជីប ជើងស្តាំឈានទៅមុខ ហើយគោរពចង្វាក់ភ្លេង) ។

- **ក្បាច់ចៅខ្វង :**

ក្បាច់នេះ ពេលអនុវត្តត្រូវធ្វើចលនាដូចតទៅ :

- បើដៃមួយនៅលើ ដៃមួយនៅក្រោម ។ ដៃលើ "ជីប" ដៃក្រោម "លា" ។ គឺដុយពីក្បាច់រាំវង់ រាំក្បាច់ ។
- ពេលចាប់ផ្តើមរាំដៃទាំងពីរនេះនឹងដដែល គ្រាន់តែបង្វិលកដៃប៉ុណ្ណោះ ពោលគឺបង្វិលពី "ជីប" ទៅ "លា" ។ ពី "លា" ទៅ "ជីប" វិញ ។
- ចំពោះជើង បើដៃស្តាំ "ជីប" ជើងឆ្វេងបោះជំហានទៅមុខ ហើយឋិតនៅក្នុងចង្វាក់ភ្លេងមួយ ។

- **ក្បាច់ត្លុកនារី :**

ចលនាក្បាច់នេះ មានចលនាត្រៀមដូចតទៅ :

- ដៃឆ្វេង "ស្នួយ" ត្រឹមចុងចិញ្ចើម ។ ដៃស្តាំ "លា" ទំលាក់មកក្រោមត្រឹមចង្កេះ ។ (ត្រៀម)
- ពេលរាំកាលណាជើងស្តាំឈាន ចង្កេះខាងស្តាំផ្សៀងស្របគ្នា ។ ចំពោះកដៃនៅដដែលពុំមានផ្លាស់ប្តូរ (ចលនាបង្វិលដូចក្នុងចលនាត្រៀម) ។

- **ក្បាច់អាឡេ :**

ចលនាក្បាច់នេះគឺ :

- ចលនាដំបូងប្រើដៃពីរ ដៃមួយខ្វងទៅលើ(ត្រឹមចិញ្ចើម) ដៃមួយទៀតខ្វង[១] ទៅក្រោមត្រឹមផ្ចិត រួចចាប់ខ្វងដៃមួយទៅលើដៃមួយទៅក្រោម ។
- បន្ទាប់មកបង្វិលកដៃ "លា" ស្តាំទៅឆ្វេង ឆ្វេងមកស្តាំ ឯជើងបោះទៅមុខស្របនឹងដៃដោយដាក់កែងជើងមុខលើកំរាល ។ ប៉ុន្តែចំពោះជើង បោះទៅក្រោយត្រូវទំលាក់ចុះចំងាយពីគ្នា ១២ សង់ទីម៉ែត្រ ។

- **ក្បាច់អាលំគំផាត់ :**

ចលនារាំមាន :

- ចលនាត្រៀមក្បាច់នេះ គឺដៃទាំងពីរបង្វិល "លា" ដៃមួយនៅលើ ដៃមួយនៅក្រោម( ចាប់បង្វិលពីក្រោមចុងដង្ហើមទៅលើ) ។

ចំណែកជើងត្រូវបោះឈានទៅមុខ ដៃបង្វិលដដែល ។ បើបោះឈានមកក្រោយចុងជើងទំលាក់ចំងាយពីគ្នា ១៥ ស.ម ។

- ចំពោះដៃនៅប្រើចលនាដដែល គ្រាន់តែផ្លាស់ប្តូរពីលើទៅក្រោម( ចំងាយពីគ្នា ៣០ ស.ម) ។

- **ក្បាច់ភូមា :**

ក្បាច់ភូមាប្រើជើងជាមូលដ្ឋានសំខាន់ :

(១) ធ្វើចលនាដូចការខ្វង

- ពេលរាំចាំបាច់ត្រូវប្រើជើងឆ្វេងមុន ( ពេលចេញដំណើរ ) ។
- ពេលដើររាំខុសពីក្បាច់មុនៗ គឺជើងបោះទៅមុខរាងបញ្ឆិត ។ ឯដៃក្រពាត់ទៅក្រោយត្រឹមចង្កេះ ។
- មុនពេលបោះជើងត្រូវបន្ទន់ពាក់កណ្តាលចំងាយពីជើងមួយទៅជើងមួយ ២៥ស.ម ។ ចំពោះទំងន់ដងខ្លួនសង្កត់នៅលើជើងក្រោយ ។

- **ក្បាច់នារីលខ្មែរ :**

ក្បាច់នេះប្រើដៃជាមូលដ្ឋានសំខាន់ :

- ពេលរាំ( ប្រើដៃឆ្វេង) ដៃម្ខាង"ជីបឡើង" ទៅលើត្រឹមចិញ្ចើមមុខសំលឹងទៅរកដៃ "ជីប" ។ ឯជើងលាតទៅមុខ ។ ដៃម្ខាងទៀតលាត្រឹមចិញ្ចើម
- ពេលចេញដំណើរ បើដៃឆ្វេង"ជីប"ត្រូវឈានជើងស្តាំ ។ ឯដៃបង្វិលពី "ជីប" ទៅ "លា" ពី"លា" ទៅ "ជីប" ។ ជើងត្រូវផ្លាស់ប្តូរទៅតាមដៃ ( ពីដៃឆ្វេង-ជើងស្តាំ ដៃស្តាំ-ជើងឆ្វេង) ។

- **ក្បាច់ស៊ីនួន :**

ក្បាច់នេះប្រើចង្កេះជាមូលដ្ឋាន :

- ពេលរាំដៃមួយនៅលើ ដៃមួយទៀតនៅក្រោម( ស្តាំ ឬឆ្វេង) ដៃលា ។
- ពេលចេញដំណើរដៃស្តាំបង្វិលកដៃ ហើយវាស៊ិតនៅខាងលើដៃឆ្វេងដែលបង្វិលនោះជានិច្ច ។
- ជើងផ្លាស់ប្តូរ ( ដៃស្តាំ ជើងឆ្វេង-ដៃឆ្វេង ជើងស្តាំ)

- **ក្បាច់ដើរសេក ឬដើរថ្លៃ :**

ក្បាច់នេះជាក្បាច់ប្រើ "លា" ។ គឺប្រើសំរាប់តួយក្សរាំ តួនាយរោង ប្រើពេលត្រូតពលពេលចេញប្រយុទ្ធប្រឆាំងគ្នា ក្នុងល្ខោនខោលស្បែក ឬប្រើសំរាប់តួអង្គមានឋានៈធំ ដំណើរមានរាងសង្ហាមានអំណាចខ្លាំងក្លា ។

- ពេលរាំលើកជើងឆ្វេងបន្ទន់ ជើងស្តាំបញ្ឈរត្រង់ទប់ដងខ្លួន ។
- ពេលចេញដំណើរលើកជង្គង់បើក ដៃលាពត់ចង្កេះដើរផ្សៀងមកស្តាំ ។
- ជើងឆ្វេងលើកឈានមុខមើលមកចុងដៃឆ្វេង ។ បើជើងស្តាំឈានទៅមុខត្រូវមើលត្រង់ទៅខាងមុខ ។

- **ក្បាច់ដើរនា :**

ក្បាច់នេះសំរាប់ធ្វើអោយជើងមានកំលាំងទប់ដងខ្លួនបាន ។

- ពេលរាំត្រូវបន្ទន់ជង្គង់ចុះ ទាញជើងអោយញែកចេញពីគ្នា បើកលាម[២] អោយស្រឡះ ។ ឯដៃទាំងពីរដាក់លើស្មា ។ កំភួនជើងសងខាងកុំអោយប៉ះដល់សាច់ភ្លៅ ។
- ចំពោះដងខ្លួនដំបូងបញ្ឈរអោយត្រង់ ។ លុះពេលចេញដើរ បើឈានជើងឆ្វេងត្រូវរុញស្មាស្តាំអោយផ្សៀងទៅមុខ ។ បើឈានទៅស្តាំរុញស្មាឆ្វេងផ្សៀងទៅមុខ ឯចង្កេះត្រូវផ្សៀងទៅតាមស្មាដែលរុញ ។

( នៅមានត )

លោក : ទេព ឡឿន ប្រធានការិ.អប់រំ
និង គ្រប់គ្រងនៃមហាវិទ្យាល័យគរុកោសល្យ

(២) បើកក្បាលជង្គង់កន្ទែក ភ្នែកសំលឹងទៅមុខអោយឆ្ងាយ

# កំណើតនៃការអប់រំសីលធម៌

## ១_ កំណើតអប់រំសីលធម៌នៅមជ្ឈិមប្រទេស :

តាមការស្រាវជ្រាវរបស់ប្រវត្តិវិទូ នរវិទូ សង្គមវិទូ និង ទស្សនវិទូជាច្រើនរូប បានបង្ហាញអោយឃើញថា ប្រវត្តិ-មនុស្ស វប្បធម៌របស់មនុស្សនៅលើសកលលោកត្រូវបានគេបែងចែកជា ២ សម័យកាលធំៗ គឺ សម័យបុរេប្រវត្តិគិតចាប់ពី ១០ ០០០ ឆ្នាំ ដល់ ៤ ០០០ឆ្នាំមុនគ.ស[១] ហៅថាសម័យអារញ្ញធម៌ ឬសម័យអានារ្យធម៌ ។ ក្នុងសម័យនេះជីវភាពរស់នៅរបស់ប្រជាជនមានលក្ខណៈជាធម្មជាតិសុទ្ធសាធ ពោលគឺពួកគេមានសេចក្ដីសុខទុក្ខ មានល្អអាក្រក់ មានបញ្ញា, អវិជ្ជា មានអំណាច គ្មានអំណាច អាយុវែង ខ្លីអាស្រ័យលើធម្មជាតិ និង អាទិទេពជាអ្នកកំណត់ ។ អាកប្បកិរិយាចរិតលក្ខណៈរបស់មនុស្សមានភាពស្មោះត្រង់ ស្លូតបូត មិនចេះកេងប្រវ័ញ្ចទ្រព្យសម្បត្តិគ្នា មិនចេះដណ្ដើមអំណាចគ្នា ចេះចែករំលែកសុខទុក្ខគ្នា មានសាមគ្គីអធ្យាស្រ័យ សន្ដោសប្រណី ការពារសត្រូវរួមគ្នា ការពារមាតុភូមិ ក្រុមគ្រួសារសាច់សាលោហិត មិនចេះឆ្កឹះឆ្កៀលបង្កទំនាស់ ចងអាឃាតចំពោះមនុស្សដែលមាន ឈាមជ័រដូចគ្នា ឬអ្នករស់នៅក្នុងសង្គមជាមួយគ្នា ពោលគឺធ្វើអោយមនុស្សចេះរស់នៅជាមួយគ្នាក្នុងសង្គមអោយមានសន្តិភាពក្នុងផ្លូវចិត្ត ។ ដំណាក់កាលនេះ សីលធម៌រស់នៅរបស់មនុស្សក៏ចាប់កំណើតមានឡើង ។

កាលពី ៣ ៤០០ ឆ្នាំមុនគ.ស ជនជាតិអេស៊ីប បានបង្កើតក្រមសីលធម៌ដ៏ថ្លៃថ្លាមួយប្រពៃក្នុងសម័យបុរេប្រវត្តិ ។ ពួកគេបានបង្កើតចៅក្រមចំនួន ៤២ អង្គ នៅអមស្ដេចយមរាជដែលមានឈ្មោះថា ស្ដេចអូស៊ីរីស (osiris) ដើម្បីសួរចម្លើយព្រលឹងអ្នកដែលបានស្លាប់ទៅ ។ ក្រៅពីនេះ ជនជាតិអេស៊ីបបានបង្កើតក្រុមសីលធម៌មួយទៀត គឺមុនពេលមនុស្សស្លាប់ គេតំរូវអោយបុគ្គលម្នាក់ៗមានសច្ចាប្រណិធានសម្បថចំពោះមុខព្រះ និង មហាជនទូទៅ ដោយនិយាយថា "ខ្ញុំមិនដែលនិយាយកុហកគេទេ ខ្ញុំមិនដែលលួចទ្រព្យសម្បត្តិគេទេ ខ្ញុំមិនដែលបោកប្រាស់គេទេ ខ្ញុំមិនដែលសម្លាប់គេទេ ខ្ញុំមិនដែលប្រព្រឹត្តអាក្រក់ចំពោះអ្នកដទៃឡើយ ។ ទាំងអស់នេះ ជានិមិត្តរូបបង្ហាញភក្ដីភាព ស្មោះត្រង់របស់ជនជាតិអេស៊ីបដែលនិយមចូលចិត្តគោរពតំលៃពិត ពាក្យពិត សច្ចធម៌ យុត្តិធម៌ ស្គាល់ខុសស្គាល់ត្រូវ និង មិនប្រព្រឹត្តអំពើបាបកម្មចំពោះអ្នកដទៃទៀត ។

កាលនៅរស់ បើនរណាម្នាក់បានធ្វើអំពើល្អ ហើយពេលជិតស្លាប់បានបង្ហាញការពិតដល់មហាជនទូទៅ ដើម្បីអោយគេវិនិច្ឆ័យនូវអំពើរបស់ខ្លួន នោះពួកគេនឹងបានព្រះការពារ និង អនុញ្ញាតអោយឡើងឋានសួគ៌ បន្ទាប់ពីមរណភាព។

បន្ទាប់ពីមនុស្សបានឆ្លងផុតពីសម័យបុរេប្រវត្តិប្រមាណ ៣២០០ ឆ្នាំ មុនគ.ស គឺដំណាលនឹងកំណើតអក្សរដែរ ។ ក្នុងខណៈនោះ មនុស្សបានប្រព្រឹត្តទៅតាមគន្លងសីលធម៌របស់សាសនា និង គម្ពីរដ៏ពិសិដ្ឋ ។ ចិត្តវិទូជំនាន់នោះ បានបង្វែរចិត្តមនុស្សអោយខ្លបខ្លាចអំណាច ឬកំលាំងអាទិទេពមានរន្ទះ ខ្យល់ព្យុះសង្ឃរា ទឹកជំនន់ រញ្ជួយដី ដោយណែនាំអោយជឿស្លុងថា "ធម្មជាតិទាំងមូល គឺអាទិទេពជាអ្នកបង្កើត និង ជាបាតុភូតចំលែកផ្សេងៗជាច្រើនទៀតដែលកើតឡើងនោះ គឺបណ្ដាលមកពីកំហឹងរបស់អាទិទេព ឬក៏បណ្ដោលមកពីអាទិទេពមិនបានទទួលដង្វាយពីមនុស្សលោក ។ អាទិទេព

(១),(2) ប្រវត្តិសាស្ត្រសកលលោក : បណ្ឌិត ស៊ន សំណាង

មិនគ្រាន់តែបង្កើតធម្មជាតិ និង មនុស្សប្រុសស្រីលើភពផែនដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតទេវតា ៣ ក្រុមទៀត ។ មួយក្រុមជាក្រុមជួយថែរក្សាការពារ និង រកសេចក្តីសុខចំរើនដល់មនុស្សលោក ។ មួយក្រុមទៀត ជាអ្នកដើរបំផ្លាញចំពោះមនុស្សដែលមិនគោរពបទដ្ឋានសីលធម៌ ប្រព្រឹត្តអំពើអកុសល ឬមិនបានធ្វើពិធីបុណ្យផ្សេងៗដល់អាទិទេព ។ ចំណែកទេវតាមួយក្រុមផ្សេងទៀត គឺជាទេវតាចាំស្វែងរកយុត្តិធម៌ កាត់សេចក្តីខុសត្រូវចំពោះមនុស្សដែលបានប្រព្រឹត្តអំពើអាក្រក់ផ្សេងៗកាលពីនៅរស់ ។ លោក ហ្សង់ ហ្សាក់រ៉ូស្សូ (J.J Rousseau) បានពោលថា "សីលធម៌មានកំណើតពីអាទិទេព ពោលគឺលោកបានចាត់ទុកសីលធម៌ជាចៅក្រមដ៏ត្រឹមត្រូវបំផុតរបស់មនុស្សជាតិទូទៅ"[៣] ។ ស្របជាមួយគ្នានេះ លោក Likewist Quran បានពោលថា "ខ្លឹមសារនៃគម្ពីរប៊ីបរបស់សាសនាគ្រីស្ត បានបង្កើតមូលដ្ឋានគ្រឹះនៃការអប់រំសីលធម៌ក្នុងសម័យបុរាណកាល ។ លោកបានបន្តទៀតថា ខ្លឹមសារនៃមាតិកានៃការអប់រំសាសនា ក្នុងសាសនាអ៊ីស្លាម ក៏ត្រូវបានគេអនុម័តដាក់បញ្ចូលក្នុងសាលា ហៅរអ៊ីស្លាមសំរាប់អប់រំសីលធម៌ដែរ"[៤] ។

ដូចនេះ យើងអាចសន្និដ្ឋានថា ការអប់រំសីលធម៌មានកំនើតនៅបស្ចិមប្រទេស តាំងពីមុនគ.ស ពោលក្នុងសម័យបុរេប្រវត្តិ ។ វាកើតឡើងពីតំរូវការរបស់មនុស្សក្នុងសម័យបុរាណ ហើយកើតពីប្រភពសាសនា ទំនៀមទំលាប់ប្រពៃណីសាសនា ។

## ២. កំណើតអប់រំសីលធម៌នៅប្រទេសកម្ពុជា :

សម័យមុនគ.ស ប្រទេសកម្ពុជាជាកុលសម្ព័ន្ធមួយមាន ភាសា វប្បធម៌ ជំនឿសាសនា។ល។ របស់ខ្លួនរួចស្រេចទៅហើយ ។ លុះនៅសតវត្សទី ១ ប្រទេស កម្ពុជាបានទទួលយកនូវជំនឿថ្មីមួយទៀតតាមរយៈឥទ្ធិពលវប្បធម៌ឥណ្ឌា ដូចជា សាសនា ប្រពៃណី រដ្ឋបាល របបគ្រប់គ្រង។ល។ ឥទ្ធិពលឥណ្ឌាមានលក្ខណៈត្រូវគ្នានឹងផ្នត់គំនិតវប្បធម៌ខ្មែរដើម ទើបធ្វើអោយវប្បធម៌បានគង់វង្សយូរអង្វែង។

ទោះបីប្រជាជនខ្មែរក្នុងសម័យកាលនោះមានចំណេះដឹងតិចតួចក៏ពិតមែន ក៏ពួកគេមានចិត្តទៀងត្រង់ មិនចេះភូតភរកុហកបោកប្រាសគ្នាទៅវិញទៅមក បើគេស្រលាញ់នរណាហើយ គេស្រលាញ់អស់ពីពោះអស់ពីពុង គេស្មោះត្រង់នឹងគ្នា គោរពចាស់ទុំ គេមិនហ៊ានប្រព្រឹត្តអ្វីអោយខុសឆ្គងពីក្រមសីលធម៌នោះទេ ។ ផ្ទុយទៅវិញ បើសិនមាននរណាម្នាក់ប្រព្រឹត្តអំពើអ្វីមួយអោយខុសពីវិន័យបញ្ញត្តិ នោះមេកន្ទ្រាញព្រមទាំងសមាជិកក្នុងសង្គមទាំងអស់នាំគ្នាថ្កោលទោសទៅតាមកំហុសរបស់ខ្លួន ។ ទង្វើទាំងនេះ មេកន្ទ្រាញមានបំណងប្រាថ្នាចង់អោយសមាជិកទាំងអស់របស់ខ្លួនទាំងក្មេងចាស់ ប្រុសស្រីគោរពអោយបានត្រឹមត្រូវតាមគន្លងសីលធម៌សង្គម ។

សម័យនគរភ្នំ ( សតវត្សទី ១ ដល់ទី ៦ ) ប្រពៃណី សាសនា ទំនៀមទំលាប់ទាំងឡាយ ត្រូវបានគេប្រកាន់ខ្ជាប់ "ព្រោះគេបានចាត់ទុកថា ទំនៀមទំលាប់ប្រពៃណី សាសនា គឺជាច្បាប់ ឬជាវិន័យរបស់សង្គមមនុស្សដែលត្រូវបានគេគោរពចាប់តាំងពីកុមារភាពទៅ" ។ អ្នកស្រុកនគរភ្នំចូលចិត្តគោរពពាក្យសច្ចៈ យុត្តិធម៌ ហើយចូលចិត្តស្វែងរកការពិតណាមួយតាមវិធីពូតបាយជាពំនូតតូចៗយកទៅថ្វាយចំពោះព្រះភក្ត្រទេវតា រួចអង្វរទេវតាអោយជួយស្វែងរកជនទុច្ចរិតដែលបានលួចរបស់នោះ ។ ស្អែកឡើងម្ចាស់ដែលបានបាត់របស់នោះ បានយកពំនូតបាយតូចៗទៅចែកចាយដល់ជនដែលមានគេសង្ស័យនៅក្នុងផ្ទះ ។ គេជឿថា មាត់របស់ជនទុច្ចរិតពិតជាមានឈាមហូរចេញ រីឯជនសុចរិតវិញ អាច

(៣) មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ភ្នំពេញ ឆ្នាំ២០០២,(៥) ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអាណាចក្រភ្នំ( ស.វទី១-៦):បណ្ឌិត មីសែល ត្រាណេ

(4) Cf. RADHASYM SARANGI (Moral Education in school, Bages and implication), New Delhi, 1994 p.2

បរិភោគបាយបានយ៉ាងងាយ មានសុខភាពមាំមួន ។ ឯកសារខ្លះបានអះអាងថា ជនដែលគេសង្ស័យត្រូវបានគេបង្អត់បាយចំនួន ៣ ថ្ងៃ បន្ទាប់មកគេអោយជនសង្ស័យលូកដៃចូលក្នុងទឹកខ្លះកំពុងពុះ ។ បើអ្នកដែលគេចោទប្រកាន់នោះជាជនស្លូតបូត ពុំបានលួចសម្បត្តិគេទេ នោះគេពុំរលាកដៃឡើយ ។ ជូនកាលទៀត គេបង្ខំអោយជនសង្ស័យនោះលូកដៃយកផ្លែពូថៅ ឬច្រវាក់កំពុងដុតក្រហមឆ្អិនឆ្អៅអោយដើរ ៧ ជំហាន ។ អ្នកគ្មានកំហុសពិតជាមិនរលាកទេ ចំណែកឯអ្នកបាន ប្រព្រឹត្តអំពើអាក្រក់ ពិតជារលាករលួយសាច់ដៃភ្លាមៗមិនអាចរង់ចាំនៅបានយូរទេ ។ ពួកអ្នកស្រុកគេជឿថា ដៃស្តាំជា និម្មិតរូបនៃអំពើល្អ ឯដៃឆ្វេងវិញជានិម្មិតរូបនៃអំពើអយុត្តិធម៌ ។

ដូចនេះនៅប្រទេសកម្ពុជា ពិតជាមានការអប់រំសីលធម៌តាំងពីយូរយារណាស់មកហើយ ពោលគឺចាប់ពីសម័យនគរភ្នំមកម្ល៉េះ ប៉ុន្តែគ្រាន់តែក្បួនច្បាប់នៃការអប់រំសីលធម៌ក្នុងសម័យកាលនោះ ពុំទាន់បានចែងចងជាច្បាប់ ជាមាត្រាជាជំពូក ។ល។ នោះទេ តែវាស្ថិតនៅក្នុងលក្ខណៈជំនឿជាប្រពៃណី សាសនា ចិត្តសាស្ត្រ ការគោរពសម្បថទៅវិញ ។ ស្របនឹងគំនិតរបស់លោក ឆាល ហាលីហ្សេ (Charles Hallisey) ដែលបានអះអាងលើពាក្យ "Ethics" (ប្រភពមកពីពាក្យ ក្រិចថា Ethikos) មានន័យថាឥរិយាបថ សីលធម៌ ចរិតលក្ខណៈ ជំនឿ ដែលទាក់ទងនឹងទំនៀមទំលាប់សាសនា សំរាប់យកមកអប់រំមនុស្សអោយដើរតាមគន្លងត្រឹមត្រូវមួយប្រកបដោយគតិយុត្ត និង ធ្វើអោយសង្គមមនុស្សមានសន្តិភាព ស្មេរភាព ថាមពល និង ការអភិវឌ្ឍ ។

ជាទូទៅ ការអប់រំសីលធម៌មានកំណើតចេញពីប្រភព ២ ផ្សេងគ្នា គឺ៖

- ប្រភពទី ១ ចេញពីសាសនា ប្រពៃណី ទំនៀមទំលាប់ហៅថា សីលធម៌សកល (universalist moral) ។ សីលធម៌បែបនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសតិអារម្មណ៍ ផ្នត់គំនិតរបស់មនុស្ស ចាប់តាំងពីមនុស្សចាប់កំណើតមក ហើយមិនងាយរលាយសាបសូន្យទៅវិញងាយៗនោះទេ ព្រោះមានតំណពីជីដូនជីតា ម្តាយឪពុកចាស់ព្រឹទ្ធាចារ្យមកម្ល៉េះ តែអាចប្រែប្រួលក្នុងករណីផ្លាស់ប្តូរទីកន្លែង សាសនា សញ្ជាតិ របបនយោបាយក្នុងពេលវេលាណាមួយ ។
- ប្រភពទី ២ កើតចេញពីឥទ្ធិពលវប្បធម៌បរទេសហៅថាសីលធម៌ពីកំណើត (Ethical relativist) ដូចជាតាមរយៈការបង្ហាញម៉ូត ការស្លៀកពាក់ ការនិយាយស្តី ការរស់នៅ ។ល។ ឥទ្ធិពលវប្បធម៌ បែបនេះគេងាយទទួលយកណាស់ ជួនកាលគេទទួលយកតាមរយៈទម្លាប់ប្រចាំថ្ងៃរបស់គេដោយមិនដឹងខ្លួន ប៉ុន្តែវាក៏ងាយសាបរលាបទៅវិញដែរ ។

(នៅមានត)

លោក : **គួយ សូគាន**

មន្ត្រីផ្នែកអប់រំនៃរាជបណ្ឌិតសភាកម្ពុជា

✤✤✤✤ ✤✤✤✤



## ចិត្តវិទ្យា- -អប់រំ

# ការអប់រំជាវិទ្យាសាស្ត្រផង និង ជាសិល្បៈផង(*)

ការអប់រំជាលំនាំមួយដែលមានគោលដៅអភិវឌ្ឍធនធានមនុស្ស ។ កុមារបន្ទាប់ពីរៀនចប់ប្រព័ន្ធអប់រំគេនឹងក្លាយទៅជាពលរដ្ឋល្អមានចំណេះដឹង និង មានប្រយោជន៍សំរាប់ប្រទេសជាតិ និង ពិភពលោកយើងនេះ ។

ជាទូទៅគោលដៅអប់រំតែងតែមាន ៤ ចំណុចសំខាន់ៗដូចខាងក្រោម ÷

១- ផ្ដល់ជូនមនុស្សជំនាន់ក្រោយនូវចំណេះដឹង ទ្រឹស្ដីវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ អរិយធម៌របស់ជនជាតិខ្លួន និង អន្តរជាតិ ។

២- ត្រៀមលក្ខណៈវិជ្ជាជីវៈតាមរយៈការអប់រំបំណិនជំនាញ និង បំណិនជីវិត

៣- អប់រំសីលធម៌ពលរដ្ឋវិជ្ជាអោយក្លាយជាពលរដ្ឋល្អ គោរពច្បាប់ មានឧត្ដមគតិស្នេហាជាតិ មាតុភូមិ ពលរដ្ឋដែលប្ដេជ្ញាចិត្តកសាងសង្គមប្រជាធិបតេយ្យដូចប្រទេសប្រជាធិបតេយ្យជើងចាស់ មានប្រទេស អង់គ្លេស បារាំង សហរដ្ឋ អាមេរិកជាដើម ។

៤- អប់រំអោយចេះរស់នៅជាមួយគ្នាដោយសន្តិវិធី ។

ដើម្បីសំរេចឧត្ដមគតិខាងលើអ្នកអប់រំទាំងឡាយត្រូវប្រកាន់គំនិតថា "ការអប់រំជាវិទ្យាសាស្ត្រផង និង ជាសិល្បៈផង" ។

តើការអប់រំជាវិទ្យាសាស្ត្រមានន័យយ៉ាងណា ?

កាលណាយើងនិយាយអំពីវិទ្យាសាស្ត្រ គឺនិយាយអំពីគោលការណ៍ច្បាប់ដែលអ្នកអប់រំទាំងអស់ត្រូវតែយល់ដឹងនឹងយកទៅអនុវត្ត ។ តើច្បាប់អ្វីខ្លះដែលអ្នកអប់រំត្រូវចេះ ?

មានច្បាប់ច្រើនណាស់ដែលចាំបាច់ត្រូវតែខំសិក្សាស្វែងយល់ និង អនុវត្តដូចជា :

- **ច្បាប់ចិត្តវិទ្យា**
  - កុមារទើបនឹងកើតរហូតអាយុពីរឆ្នាំ ត្រូវទទួលការរៀនសូត្រតាមរយៈសកម្មភាពជាមួយឧបករណ៍សំរាប់កុមារ
  - ចាប់ពីអាយុពីរឆ្នាំ ដល់ អាយុ ៦ ឆ្នាំ កុមាររៀនតាមរយៈដើរតួក្នុងល្បែង

* ទស្សនៈអ្នកប្រាជ្ញអង់គ្លេស

- ចាប់ពីអាយុ ៧ ឆ្នាំ ដល់អាយុ ១២ ឆ្នាំ កុមាររៀនតាមរយៈមាតិកាពីរូបិយទៅអរូបិយ
- ចាប់ពីអាយុ ១២ឆ្នាំឡើងទៅជិតទង់ អាចមានសមត្ថភាពគិតតាមបែបអរូបិយចេះធ្វើប្រមាណវិធីដោយពេញលក្ខណៈត្រឹមត្រូវ
- កុមាររៀនបានល្អតាមរយៈសកម្មភាពផ្ទាល់ខ្លួន
- ម្តាយឪពុកត្រូវជួយអប់រំកុមារតូចតាមរយៈនិទានរឿងអោយកុមារតូចស្តាប់
- កុមារត្រូវអភិវឌ្ឍផ្នែកភាសាជាមុនសិន ហើយភាពរីកចំរើននៃភាសាជាកត្តាអោយកុមារបានទទួលជោគជ័យផ្នែកមុខវិជ្ជាដទៃទៀតមានគណិតវិទ្យា វិទ្យាសាស្ត្រជាដើម
- ការអប់រំអោយមានទំលាប់ល្អ ការអប់រំសីលធម៌មានឥទ្ធិពលល្អណាស់នៅពេលដែលកុមារនៅវ័យក្មេង សមដូចសុភាសិតខ្មែរយើងពោលថា "ពត់ឫស្សីទាន់វានៅខ្ចី" "រំដំដែកទាន់នៅក្តៅ" ពោលគឺ ការអប់រំទៅតាមច្បាប់ចិត្តវិទ្យាស្តីអំពីដំណាក់កាលអភិវឌ្ឍតាមវ័យ មានប្រសិទ្ធភាពណាស់ ។

- **ច្បាប់ក្នុងគរុកោសល្យ**
  - ការអប់រំសំរាប់ទាំងអស់គ្នា
  - ការអប់រំត្រូវតែអនុវត្តដោយឡែក១ពីគ្នា
  - ការអប់រំត្រូវតែធ្វើអោយសំរេចបានចតុសុទ្ធ
  - ការអប់រំតាមគោលការណ៍ទាក់ទិនង
  - ការអប់រំត្រូវតែមានការចូលរួមអំពីសហគមន៍ និង ដើម្បីសហគមន៍
  - ការអប់រំមានគ្រប់ទីកន្លែង និង គ្រប់ពេលវេលា
  - ការអប់រំសីលធម៌ត្រូវធ្វើព្រមគ្នាជាមួយនឹងការអប់រំផ្នែកចំណេះដឹង ផ្នែកសតិអារម្មណ៍និងផ្នែកអំពើ-៧-
  - ការអប់រំវិទ្យាសាស្ត្រត្រូវដើរតាមមាគ៌ា ៥ ជំហាន : ១.ការដាក់បញ្ហា, ២.ការលើកឡើងសម្មតិកម្ម ៣.ការពិសោធ និង ការប្រមូលទិន្នន័យ, ៤.ការវិភាគទិន្នន័យ, និង ៥.ការសន្និដ្ឋាន ។
  - យើងអាចវាយតំលៃគុណភាពបានតាមរយៈការបង្កើតឡើងនូវសញ្ញាសំគាល់សមត្ថភាពប្រតិបត្តិ (Performance indicator) ។
  - ការសិក្សាអប់រំត្រូវប្រព្រឹត្តទៅអស់មួយជីវិត

☆ ច្បាប់ក្រមសីលធម៌ ១២ ប្រការរបស់គ្រូ :

ឯសារអន្តរជាតិដែលទាក់ទងនឹងក្រមសីលធម៌របស់គ្រូបង្រៀនបានចែងនូវក្រមសីលធម៌១២យ៉ាងដូចខាងក្រោម:

- បង្ហាញថាគ្រូមានការជឿជាក់ទៅលើសមត្ថភាពរៀនរបស់សិស្ស
- ផ្តល់កិច្ចការដល់សិស្សទាក់ទងនឹងខ្លឹមសារដែលបានបង្រៀន
- បង្រៀនសិស្សអោយចេះទទួលខុសត្រូវ និង ទទួលបានបទពិសោធន៍ជីវិត
- យុត្តិធម៌តលំអៀងចំពោះសិស្សគ្រប់រូប
- ធ្វើគំរូល្អដល់សិស្ស

- បង្ហាញអោយឃើញនូវសកម្មភាពដែលបញ្ជាក់ថាខ្លួនស្រលាញ់វិជ្ជាជីវៈ
- រៀនហើយរៀនទៀត ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈ
- ទំនាក់ទំនងល្អជាមួយមាតាបិតាសិស្ស
- ទទួលស្គាល់ និង ប្រកាន់យកសហគមន៍ជាដៃគូក្នុងការអប់រំ
- រក្សាការសំងាត់រវាងគ្រូ និង សិស្ស
- ប្រកាន់ខ្ជាប់ខ្លួននូវគោលនយោបាយ វិន័យ និង ច្បាប់ ។

ដូចនេះលក្ខណៈវិទ្យាសាស្ត្រក្នុងការអប់រំចង់និយាយថា អ្នកអប់រំទាំងឡាយដែលបំរើការងារអប់រំត្រូវរៀនអោយបានយល់ច្បាស់ពីបណ្តាទ្រឹស្តី និង គោលការណ៍នៅក្នុងចិត្តវិទ្យា វិធីសាស្ត្របង្រៀន ព្រមទាំងទ្រឹស្តីនៅក្នុងជំនាញឯកទេសរបស់ខ្លួនអោយបានច្បាស់លាស់ដូចជាទ្រឹស្តីនៅក្នុងវិទ្យាសាស្ត្រ ទ្រឹស្តីអក្សរសិល្ប៍ ទ្រឹស្តីនៃការបង្រៀន វិទ្យាសាស្ត្រក្បួនច្បាប់ទាំងឡាយនៃការពិសោធវិទ្យាសាស្ត្រ ។ល។

អ្នកអប់រំ លោកគ្រូ អ្នកគ្រូបង្រៀនទាំងឡាយត្រូវតែរៀនអោយបានយល់ច្បាស់ក្បួនច្បាប់ទ្រឹស្តីទាំងនេះ ព្រមទាំងយកមកអនុវត្តនៅក្នុងសកម្មភាពអប់រំដោយហ្មត់ចត់ជាទីបំផុត ។

ចំណុចទីពីរ ស្តីអំពី "ការអប់រំជាសិល្បៈ" សុភាសិតខ្មែរយើងបានពោលថា "ចេះដប់មិនស្មើប្រសប់មួយ" បានសេចក្តីថា អ្នកចេះទ្រឹស្តីជ្រៅជ្រះក្តីក៏មិនសុទ្ធតែបានទទួលជោគជ័យក្នុងការអប់រំដែរ ព្រោះថាការអប់រំជាវិទ្យាសាស្ត្រផង និង ជា "សិល្បៈផង" ។ កាលណានិយាយទៅដល់សិល្បៈគឺនិយាយអំពីភាពទន់ភ្លន់ ភាពបត់បែនប្រកបទៅដោយលក្ខណៈច្នៃប្រឌិតទៅតាមសភាពការណ៍ជាក់ស្តែង ។ ដូចនេះអ្នកអប់រំទាំងឡាយចាំបាច់ណាស់ ដែលត្រូវតែយកទ្រឹស្តីអប់រំទាំងនោះមកអនុវត្តដោយគំនិតច្នៃប្រឌិតទៅតាមសភាពជាក់ស្តែងនៃកម្មវត្ថុ និង ប្រធានវិស័យដែលត្រូវទទួលការអប់រំ ។ តាមន័យនេះ អ្នកអប់រំត្រូវយល់ដឹងអំពីតំរូវការរបស់អ្នករៀន តំរូវការរបស់សង្គមនាសម័យកាលបច្ចុប្បន្ន និង អនាគត ។ ផ្អែកលើការយល់ដឹងទាំងនេះ អ្នកអប់រំត្រូវគិតទុកជាមុននូវបញ្ហាដែលត្រូវជួបប្រទះដើម្បី រៀបចំផែនការសកម្មភាព និង អនុវត្តសកម្មភាពគ្រប់គ្រងអប់រំ សកម្មភាពបង្រៀនដោយគំនិតច្នៃប្រឌិតទៅតាមទ្រឹស្តីច្បាប់ និង តំបន់ វិទីកន្លែងដែលខ្លួនទទួលខុសត្រូវអប់រំ ។ ពាក្យស្លោកមួយបានពោលថា : "what motivates people is what motivates people" (Ken Blanchard) បានន័យថាកំលាំងជំរុញទឹកចិត្តរបស់មនុស្សមិនដូចគ្នាទេ ។ សិស្សខ្លះ ត្រូវការការលើកទឹកចិត្ត ការរាប់អានពីគ្រូដោយពាក្យសំដី តែសិស្សខ្លះដែលខ្វះមុខខ្វះក្រោយនូវកំលាំងជំរុញអាចជាសំភារៈដែលសិស្សនោះកំពុងខ្វះខាតជាខ្លាំងនោះឯង ។

ដូចនេះហើយបានជាមានទ្រឹស្តីអប់រំមួយពោលថា "ការអប់រំត្រូវតែអនុវត្តដោយឡែក" ។

ដោយនិយាយរួមការអប់រំបានជោគជ័យអាស្រ័យនឹងចំណេះដឹងផ្ទាល់ខ្លួន ចំណេះដឹងទ្រឹស្តីវិទ្យាសាស្ត្រ និងលក្ខណៈផ្ទាល់ខ្លួនរបស់អ្នកអប់រំដែលជាមនុស្សចូលចិត្តកុមារ ស្រលាញ់សិស្ស ជឿជាក់ទៅលើសិស្សមានការរាក់ទាក់ជាមួយសិស្ស សមត្ថភាពច្នៃប្រឌិត ព្រមទាំងមានការប្តេជ្ញាចិត្តធ្វើអោយសំរេចបានលទ្ធផល ល្អប្រសើរ យុត្តិធម៌ សមធម៌ ប្រសិទ្ធភាព( មិនខ្វះខ្វាយ ពេលវេលា) នេះឯង ។

បណ្ឌិត **អ៊ឹម កុច**

# ដំណើរការអភិវឌ្ឍន៍វិស័យអប់រំនៅសហរដ្ឋអាមេរិក

## I. ទស្សនៈផ្តើម

ចិត្តវិទ្យាអប់រំ មានអត្ថប្រយោជន៍យ៉ាងណាខ្លះចំពោះគ្រូបង្រៀន ?

- ជួយគ្រូបង្រៀនអោយដើរទាន់សម័យនិយម ចំពោះពត៌មានដែលកើតឡើងក្នុងការបង្រៀន និង ការអប់រំសិស្ស
- ជួយគ្រូអោយមានបទពិសោធន៍ល្អក្នុងការបង្រៀន និង ការអប់រំ
- ជួយគ្រូអោយមានដំណើរការអភិវឌ្ឍទៅតាមកិរិតវិជ្ជាជីវៈ
- ជួយគ្រូអោយលើកកំពស់កិរិតវិជ្ជាជីវៈ និង បទពិសោធន៍ក្នុងបច្ចេកទេសគរុកោសល្យ
- ជួយគ្រូអោយយល់ដឹងស៊ីជំរៅទៅលើទស្សនៈ និង បញ្ញត្តិជាមូលដ្ឋានគ្រឹះក្នុងវិធីសាស្ត្របង្រៀន និង អប់រំសិស្ស
- ជួយគ្រូអោយចេះកំណត់វត្ថុបំណង និង រៀបចំគោលវិធីបង្រៀនទៅតាមខ្លឹមសារមេរៀន

## II. លក្ខខណ្ឌលើកកំពស់ក្របខ័ណ្ឌគ្រូបង្រៀន

តើសហរដ្ឋអាមេរិកបង្កើតលក្ខខណ្ឌលើកកំពស់វិធីបង្រៀននៅក្នុងជួរគ្រូបង្រៀនយ៉ាងដូចម្តេច ?

ឆ្នាំ ១៩៨៥ ព្រឹទ្ធសភាសហរដ្ឋអាមេរិកប្រកាសថា :

- ជាឆ្នាំដឹងគុណគ្រូបង្រៀន និង ជាឆ្នាំលើកកំពស់កិត្តិយសគ្រូបង្រៀន
- ជាឆ្នាំដែលយើងទទួលស្គាល់ថា គ្រូមានតួនាទីដ៏រស់រវើកក្នុងសង្គម
- ចាប់ផ្តើមតំឡើងប្រាក់បៀវវត្សទៅតាមកិរិតរបស់គ្រូ
- ជួយអោយមូលដ្ឋានសាលារៀនមានដំណើរការអភិវឌ្ឍទៅតាមស្រុក
- ជួយអោយគ្រូបង្រៀនមានបៀវត្ស និង កំរិតគរុកោសល្យសមរម្យ [1]

## III. សម្បទានៃការគិតនៅក្នុងសង្គមដ៏ទំនើប

ឱនភាពនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ឆ្នាំ ១៩៨០ ទាមទារអោយរដ្ឋាភិបាលអាមេរិកធ្វើដូចម្តេចខ្លះ ?

- ចាប់ផ្តើមវាយតំលៃប្រព័ន្ធអប់រំជាតិឡើងវិញ នៅក្នុងកំរិតជាតិ ថាតើត្រូវអប់រំសិស្សយ៉ាងដូចម្តេច ដើម្បីអោយគេអាចចូលរួមកសាង និង អភិវឌ្ឍសង្គម
- បង្កើតអោយមានកំលាំងគណៈកម្មការជាតិ និង កំលាំងដែលមានសមត្ថកិច្ចផ្សេងៗសំរាប់ធ្វើរបាយការណ៍ និង លក្ខន្តិកៈដ៏មានអត្ថន័យសំរាប់ផ្សព្វផ្សាយអោយសាលារៀនទូទាំងសហរដ្ឋអនុវត្តតាម :
  - គណៈកម្មការជាតិជំនាញអប់រំ

(1) Thomas K.Crowleral, Educational psycho; Brown E.Benchmark, 1997,p-9

- គណៈកម្មការលើកកំពស់សមត្ថភាពអំណាន
- គណៈកម្មការអប់រំ និង សេដ្ឋកិច្ច

ក្នុងឆ្នាំ ១៩៨៥ បណ្ឌិតសភាសហរដ្ឋអាមេរិកបានធ្វើការសិក្សាប្រៀបធៀបស្នាដៃសិក្សារបស់សិស្សមធ្យមសិក្សាអាមេរិក និង សិស្សមធ្យមសិក្សាមកពីបណ្ដាប្រទេសឧស្សាហកម្មជឿនលឿន តាំងពីក្រោយសង្គ្រាមលោកលើក ទី ២ ផ្នែកគណិតវិទ្យា មកពីប្រទេសចំនួន ១៤ ជាសិស្សថ្នាក់ទី ៨ ដូចគ្នាក្នុងឆ្នាំ ១៩៨១-១៩៨២ :

| | | |
|---|---|---|
| ជប៉ុន | មានមធ្យមភាគ | : ៦៤ % |
| ហូល្លង់ | មានមធ្យមភាគ | : ៥៨ % |
| បារាំង | មានមធ្យមភាគ | : ៥៦ % |
| បែលសិច ( ផ្លេមីស) | មានមធ្យមភាគ | : ៥៦ % |
| ហុងគ្រី | មានមធ្យមភាគ | : ៥៦ % |
| អង់គ្លេស ( កូឡុំប៊ី) | មានមធ្យមភាគ | : ៥៤ % |
| បែលសិច ( ភាសាបារាំង) | មានមធ្យមភាគ | : ៥៣ % |
| ប្រទេស និង ខេត្តចំនួន ១៤ | មានមធ្យមភាគ | : ៥២ % |
| អុងតារីយ៉ូ | មានមធ្យមភាគ | : ៥០ % |
| ស្កុតឡិន | មានមធ្យមភាគ | : ៤៨ % |
| អង់គ្លេស និង វែល | មានមធ្យមភាគ | : ៤៨ % |
| ហ្វាំងឡង់ | មានមធ្យមភាគ | : ៤៨ % |
| សហរដ្ឋអាមេរិក | មានមធ្យមភាគ | : ៤៨ % |
| ណូវែលសេឡង់ | មានមធ្យមភាគ | : ៤៤ % |
| ស៊ុយអែត | មានមធ្យមភាគ | : ៤២ % |

កាលក្នុងឆ្នាំ ១៩៨៣ គេរកឃើញថា វិញ្ញាសាឯទៀតៗ ក្រៅពីគណិតវិទ្យាក៏សិស្សអាមេរិកថ្នាក់ទី ៨ នៅតែបានពិន្ទុទាបជាងគេ ក្នុងចំណោមវិញ្ញាសារួមចំនួន ១៩ ធ្វើក្នុងពេលជាមួយគ្នា[2] ។

ក្នុងឆ្នាំ ១៩៩២ ការប្រៀបធៀបស្នាដៃសិក្សារបស់និស្សិតអាមេរិក និង និស្សិតមកពីបណ្ដាប្រទេសឧស្សាហកម្មដទៃទៀត គណៈកម្មការប្រឡងបានរកឃើញថា សិស្សអាមេរិក និង សិស្សមកពីប្រទេសដទៃមានលទ្ធផលនៃស្នាដៃ សិក្សាប្រហាក់ប្រហែលគ្នា ហើយគេរកឃើញទៀតថា ៤០% នៃនិស្សិតអាមេរិកអាយុ ១៧ ឆ្នាំ មិនអាចបញ្ចេញស្នាដៃក្នុងសម្បទានៃការគិតអោយមានកំរិតខ្ពស់បានឡើយ ។

ក្នុងឆ្នាំ ១៩៩៦ : លោក Bracey បានរកឃើញថា ការប្រៀបធៀបពិន្ទុនៃស្នាដៃសិក្សារបស់សិស្សអាមេរិកជាមួយនិងសិស្សមកពីប្រទេសឧស្សាហកម្មដទៃទៀត មានគំលាតពិន្ទុខុសគ្នាបន្តិចបន្តួច ដែលទទួលបានពីការ

(2) Thomas K.Crawkcel, Edu.psy. op. cit. p.11

ចូលរួមប្រលងអន្តរជាតិ ។ គំលាតពិន្ទុខុសគ្នាបន្តិចបន្តួចនេះហើយ ដែលធ្វើអោយចំណាត់ថ្នាក់ឃ្លាតឆ្ងាយពីគ្នា ។ សូម្បីតែនិស្សិតអាមេរិកមានចំណាត់ថ្នាក់ទាបជាងនិស្សិតប្រទេស ដទៃទៀតក៏ដោយ ក៏ពិន្ទុរបស់គេមិនមែនមានន័យថា នៅទាបជាងគេដែរ ។

លោក Bracey បានរកឃើញថា ពិន្ទុខុសប្លែកគ្នារបស់សិស្សដែលមកពីប្រទេសតែមួយដូចគ្នា ឃើញថាលើសគ្នាច្រើនពីពិន្ទុរបស់សិស្សដែលមកពីប្រទេសផ្សេងៗគ្នាដែរ ហើយគាត់បានពន្យល់ថា សិស្សមកពីប្រទេសទាំងអស់មានកិរិតស្មាដៃសិក្សាស្រដៀងៗគ្នា ។ សិស្សមកពីប្រទេសដទៃដែលចូលរួមក្នុងការប្រលងជាអន្តរជាតិនេះមានកិរិតស្មាដៃលំអៀងគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។

- សហរដ្ឋអាមេរិក ជាប្រទេសដែលមានសាលារៀនច្រើនជាងគេក្នុងពិភពលោក
- សាលារៀនច្រើនបានរួមចំណែកក្នុងការពង្រឹង និង ការអភិវឌ្ឍន៍ប្រទេសជាតិ
- ប្រជាពលរដ្ឋមានសញ្ជាតិ និង វប្បធម៌ជាច្រើនផ្សេងគ្នា
- អ្នកអប់រំត្រូវប្រឈមមុខទល់នឹងបញ្ហាស្មុគស្មាញជាច្រើនជាមួយសិស្ស

លោក Bracey ទាមទារអោយមានបន្លាស់ប្តូរ ឬកំណែទំរង់យ៉ាងសំខាន់នៅក្នុងប្រព័ន្ធអប់រំអាមេរិក :

- កំណែទំរង់កម្មវិធីសិក្សា
- កំណែទំរង់សៀវភៅសិក្សា
- កំណែទំរង់វិធីសាស្ត្របង្រៀន
- កំណែទំរង់គោលការណ៍វាយតំលៃស្មាដៃសិក្សារបស់សិស្ស
- កំណែទំរង់មូលដ្ឋានសំភារៈបច្ចេកទេស[4]

ក្នុងន័យសំដៅលើកកំពស់គុណភាពអប់រំរបស់ប្រជាពលរដ្ឋអាមេរិកអោយដើរទាន់ប្រទេសមហាអំណាចឧស្សាហកម្មដទៃទៀត ។ ដូចនេះ

- នាយកសាលារៀន
- គ្រូបង្រៀន
- មាតាបិតាសិស្ស
- អាជ្ញាធរមូលដ្ឋាន
- ក្រសួងពាក់ព័ន្ធ

ត្រូវឯកភាពគ្នាពង្រឹងចំណងមិត្តភាពជាដៃគូ ក្នុងការតាមដានអប់រំ បណ្តុះបណ្តាលបុគ្គលិកលក្ខណៈយុវសិស្សអោយចុះសំរុងក្នុងសង្គម និង អនុវត្តវិធីសាស្ត្របង្រៀន និង អប់រំសិស្សអោយមានប្រសិទ្ធភាព ។

ចាប់តាំងពីអាយុ ១៧ ឆ្នាំ ឡើងទៅ យុវសិស្សមធ្យមសិក្សាត្រូវឆ្លងកាត់ :

- វិញ្ញាសាប្រលងដ៏លំបាក

(4) Thomas K.Crowleral. Edu.Psy-op-cit p-15

- ឥទ្ធិពលពាណិជ្ជកម្ម តាមបែបអាថិកំបាំងក្នុងសង្គម
- ទទួលរងវប្បធម៌នានាក្នុងសង្គម និង វប្បធម៌បរទេស
- ទទួលរងឥទ្ធិពលនៃបទប្រព្រឹត្តល្មើសក្នុងសង្គម

ដូចនេះឪពុកម្តាយ មាមីង បងប្អូនប្រុសស្រី គ្រូ នាយកសាលារៀន និង អាជ្ញាធរ ត្រូវសហការគ្នាជួយអប់រំ ណែនាំ និង ដាស់តឿនយុវសិស្សអោយដើរផ្លូវល្អ ។

នៅចន្លោះឆ្នាំ ១៩៨២-១៩៩២ ក្រុមវាយតំលៃវឌ្ឍនភាពអប់រំក្រិតជាតិបានរកឃើញថា :

- ស្នាដៃសិស្សខ្សោយមានដំណើរការអភិវឌ្ឍន៍យ៉ាងខ្លាំង
- គំលាតពិន្ទុនៃស្នាដៃសិក្សារបស់សិស្សមានលក្ខណៈប្រហាក់ប្រហែលគ្នា
- សិស្សជួបនឹងសំណូមពរដ៏តឹងតែងរបស់សាលារៀន
- សិស្សប្រលងជាប់ច្រើន បើធៀបទៅនឹងសិស្សនៅប្រទេសឧស្សាហកម្មនានា
- សិស្សមានពិន្ទុខ្ពស់ (ភាគច្រើន) ខាងផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ ។

| មុខវិជ្ជាសិក្សា | 1982 | 1987 | 1990 | 1992 |
|---|---|---|---|---|
| ធរណីមាត្រ | 48,4 | 61,5 | 64,7 | 70,4 |
| ពិជគណិត II | 36,9 | 47,1 | 49,2 | 56,1 |
| ត្រីកោណមាត្រ | 12,2 | 19,0 | 18,4 | 21,1 |
| គណនា | 4,3 | 6,2 | 6,6 | 10,1 |
| ពិជគណិត II និងធរណីមាត្រ | 29,1 | 42,4 | 44,0 | 50,1 |
| ជីវវិទ្យា | 78,7 | 88,3 | 91,6 | 93,0 |
| គីមីវិទ្យា | 31,6 | 44,8 | 49,6 | 55,5 |
| រូបវិទ្យា | 13,5 | 19,5 | 21,5 | 24,7 |
| ជីវវិទ្យា និង គីមីវិទ្យា | 28,6 | 43,0 | 48,2 | 53,9 |
| ជីវវិទ្យា,គីមីវិទ្យា,រូបវិទ្យា | 9,8 | 16,8 | 18,9 | 21,6 [3] |

## IV. ការរិះគន់ទៅលើវិធីបង្រៀន

ការរិះគន់ទៅលើវិធីបង្រៀន មិនមែនជាប្រការមួយដ៏ថ្មីស្រឡាងទេ ។ គ្រូបង្រៀន និង នាយកសាលារៀនទទួលរងការស្តីបន្ទោសឆ្លងកាត់រយៈពេលជាច្រើនឆ្នាំ ។ សំណូមពររបស់សង្គមគឺ អប់រំយុវជន សិស្ស អោយដើរទាន់សម័យដ៏ទំនើប ប្រកបដោយសីលធម៌រស់នៅចុះសំរុងក្នុងសង្គម ហើយដូវគ្រូបង្រៀនជាអ្នកមានទង្វើដ៏សកម្មនៅក្នុងសង្គម ។ ក្នុងឆ្នាំ ១៩៥៧ សហភាពសូវៀតបានបាញ់បង្ហោះយានអវកាសស្ពុតនិចដំបូងបង្អស់ទៅក្នុងអវកាសធ្វើអោយសហរដ្ឋអាមេរិកស្រឡាំងកាំង និង ប្រជាពលរដ្ឋអាមេរិកភ្ញាក់ផ្អើល ។ រដ្ឋាភិបាល និង ប្រជាពលរដ្ឋអាមេរិកសំណូមពរអោយ :

(3) Thomas K.Crowleral Edu Psycho-op cit p-12

- បង្កើតគណៈកម្មការជំនាញសំរាប់ត្រួតពិនិត្យ និង វិភាគទៅលើប្រព័ន្ធនៃកម្មវិធីសិក្សាគ្រប់កំរិតសិក្សា
- វិទ្យាសាស្ត្រអប់រំមានតួនាទីសំខាន់ណាស់នៅក្នុងកំណែប្រែកម្មវិធីសិក្សា និង វិធីសាស្ត្របង្រៀនអោយមានដំណើរការអភិវឌ្ឍន៍ ។
- បន្លាស់ប្តូរជាបន្ទាន់ខ្លឹមសាររបស់ប្រព័ន្ធកម្មវិធីសិក្សា ជាប្រការដែលសហរដ្ឋអាមេរិកត្រូវការណាស់
- រដ្ឋាភិបាលត្រូវសំលឹងមើល និង ចាត់តាំងអ្នកវិទ្យាសាស្ត្រនាំមុខ : គួរបង្រៀនសិស្សពីវិទ្យាសាស្ត្រអ្វី ? តើត្រូវបង្រៀនសិស្សយ៉ាងដូចម្តេច ?(វិធីសាស្ត្របង្រៀន) ។

ការសិក្សាវិទ្យាសាស្ត្រត្រូវអនុវត្តអោយទាន់សម័យនិយម ដោយបញ្ចូល និង ផ្សារភ្ជាប់ចំណេះដឹងថ្មីទៅនឹងយុគសម័យថ្មីនៃអវកាស ។ ការសិក្សាវិទ្យាសាស្ត្រទៅតាមប្រពៃណី និង មានមន្ទីរពិសោធន៍ជាអតិបរមា ពិតជាឋិតនៅក្នុងកំរិតខ្ពស់ គួបផ្សំនឹងវិធីសាស្ត្រដែលជំរុញអ្នកស្រាវជ្រាវអោយឈានទៅដល់របកគំហើញថ្មីៗ និង យ៉ាងទំនើបក្នុងវិធីសាស្ត្របង្រៀន ។ ឧបករណ៍សំរាប់ក្មេងលេងកំសាន្ត ត្រូវឆ្លងកាត់ការពិសោធរបស់វិទ្យាសាស្ត្រអប់រំ សំដៅបណ្តុះបញ្ញា និង បុគ្គលិកលក្ខណៈរបស់កុមារអោយដើរទាន់សម័យដ៏ទំនើបរបស់សង្គម [5] ។

សិស្សរៀនបានល្អដោយសារ :

- សិស្សមានទំលាប់ស្គាល់ឧបករណ៍លេងកំសាន្ត តាមបទពិសោធនៃវិទ្យាសាស្ត្រអប់រំ
- សិស្សចេះស្រាវជ្រាវស្វែងយល់តាមរយៈឧបករណ៍លេងកំសាន្ត ដែលផ្សារភ្ជាប់ទៅនឹងខ្លឹមសារមេរៀន ឬជីវភាពរស់នៅធម្មតាក្នុងសង្គម
- សិស្សមានទំលាប់ស្វែងយល់ និង ឈានដល់របកគំហើញដោយខ្លួនឯង(គោលវិធីសិស្សមជ្ឈមណ្ឌល)
- គំនិតស្រាវជ្រាវ និង របកគំហើញដ៏ទូលំទូលាយរបស់ចិត្តវិទូ គរុកោសល្យវិទូ និង ទស្សនៈវិទូ ។

## ១- ការបញ្ជាក់ពីកត្តាទាំងឡាយដែលបានធ្វើសម្ពាទានដល់ការទិតៀនលើវិស័យអប់រំនៅសហរដ្ឋអាមេរិកការអប់រំ និង សេដ្ឋកិច្ច

ឱនភាព និង ការប្រកាសអាសន្នពីវិស័យអប់រំ និង សេដ្ឋកិច្ចធ្វើអោយសហរដ្ឋអាមេរិក :

- មានបទពិសោធន៍ក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចនាំមុខរបស់ពិភពលោក
- ការប្រកាសអាសន្ននេះធ្វើឡើងដោយផ្តល់នូវចំណុចសំខាន់១ដ៏ទូលំទូលាយអំពីលក្ខខ័ណ្ឌរបស់វិស័យអប់រំទូទាំងប្រទេស
- សិស្សដែលកំពុងរៀនក្នុងសាលារៀនសព្វថ្ងៃជាកំលាំងអភិវឌ្ឍនៃការងារក្នុងសង្គមទៅអនាគត
- ថ្នាក់ដឹកនាំប្រទេសជាតិ ត្រូវមានទំនាក់ទំនងជាមួយសាលារៀន សំដៅជួយណែនាំក្នុងការផលិតធនធានមនុស្ស និង លើកកំពស់កំរិតយល់ដឹងរបស់ប្រជាពលរដ្ឋដែលអាចប្រកួតប្រជែងបានប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារបច្ចេកទេសអន្តរជាតិកំរិតខ្ពស់។ ដូចនេះបានន័យថាអប់រំនាំមុខសេដ្ឋកិច្ច ។

(5) Thomas K.Crowleral. Edu.Psycho-op-cit p-16

## ២. ចំណងទាក់ទងរវាងលក្ខខណ្ឌក្នុងសាលារៀន និង ការសិក្សារបស់សិស្ស

នៅឆ្នាំ ១៩៧៥ លោកស្រី Lortie បានជំរុញអោយអ្នកស្រាវជ្រាវ :

- ធ្វើការស្រាវជ្រាវទៅលើជូរគ្រូបង្រៀននៅតាមសាលារៀនអំពីវិធីសាស្ត្របង្រៀន
- យកចិត្តទុកដាក់ពិនិត្យពិច័យទៅលើចំណងទាក់ទងគ្នារវាងលក្ខខណ្ឌនៅក្នុងសាលារៀន និង ការសិក្សារបស់សិស្ស

ក្រុមអ្នកស្រាវជ្រាវបានរកទៅឃើញថា សិស្សទទួលបរាជ័យក្នុងការសិក្សាបណ្ដាលមកពី :

- សិស្សមិនបានយកចិត្តទុកដាក់ក្នុងការសិក្សា
- មានកត្តាជាច្រើនខាងក្នុង និង ខាងក្រៅសាលារៀនដែលធ្វើអោយសិស្សមិនខំរៀន
- សិស្សមិនអាចប្រលងជាប់តាមស្តង់ដានៃវិញ្ញាសាឡើយ
- គ្រូមិនបានរៀបចំរចនាសម្ព័ន្ធក្នុងកិច្ចតែងការបង្រៀន ឬមិនកំណត់វត្ថុបំណងនៃការសិក្សាអោយបានច្បាស់លាស់
- គ្រូមិនយកចិត្តទុកដាក់សម្លឹងមើលសេចក្ដីសង្ឃឹមរបស់សិស្ស
- សាលារៀនមិនបានពង្រឹង ឬវាយតំលៃទៅលើស្នាដៃសិក្សារបស់សិស្ស
- អត្ថន័យនៃខ្លឹមសារមេរៀន មិនផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់សិស្ស ឬមិនអាចអោយសិស្សអនុវត្តបាន ។

## ៣. អត្ថប្រយោជន៍នៃសម្បទាក្នុងការគិតកំរិតខ្ពស់

ក្នុងឆ្នាំ ១៩៩៥ លោក Sato និង លោក Mc.Laughlin បានយកចិត្តទុកដាក់ដល់ :

- ការប្រៀបធៀបស្នាដៃសិក្សារបស់សិស្សមកពីប្រទេសនានា
- ការប្រៀបធៀបវប្បធម៌រស់នៅផ្សេងៗគ្នារបស់សិស្សក្នុងសង្គម
- អត្ថប្រយោជន៍ និង ចំណង់ចំណូលចិត្តរបស់សិស្សផ្នែកវិជ្ជាជីវៈក្នុងសង្គម

} សំដៅលើកកំពស់សម្បទានៃការយល់ដឹងរបស់សិស្ស

ទំហៀបបុគ្គលិកលក្ខណៈ និង ការយកចិត្តទុកដាក់របស់គ្រូសញ្ជាតិផ្សេងៗគ្នាឃើញថាគ្រូបង្រៀនជប៉ុនផ្ដោតស្មារតីទៅលើ :

- ការពង្រឹងស្មារតីរបស់សិស្សក្នុងការយល់ដឹង
- បំណិនរបស់សិស្សនៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ
- វិធីដែលអាចជំរុញសិស្សអោយមានការរីកចំរើននៅក្នុងទំនាក់ទំនងសង្គម
- វិធីដែលអាចជួយសិស្សអោយមានទំនួលខុសត្រូវលើខ្លួនឯង និង ចំពោះសមូហភាព
- វិធីដែលអាចធ្វើអោយសិស្សមានពេលវេលាច្រើននៅក្នុងសាលារៀនក្នុងមួយថ្ងៃៗ

ទំហៀបស្នាដៃនៃពិន្ទុប្រលងរបស់សិស្សមកពីប្រទេសដែលមានវប្បធម៌ផ្សេងគ្នា និង វិស័យសងមសេដកិច

ខុសប្លែកគ្នា សអោយឃើញថា កត្តាវប្បធម៌នេះឯងដែលរួមចំណែកដល់ការសិក្សារបស់សិស្សក្នុងការបញ្ចេញស្នាដៃសិក្សាអោយឃើញខុសប្លែកគ្នា ។

ក្នុងឆ្នាំ ១៩៩៥ គណៈកម្មការជាតិទ្រទ្រង់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន បានលើកឡើងនូវចំណុចជាស្តង់ដារបស់គ្រូដែលមានបទពិសោធន៍ល្អមាន ៥ ចំណុច :

១- ជាគ្រូដែលតស៊ូប្តូរផ្តាច់ចំពោះសិស្ស និង ការសិក្សារបស់សិស្ស

២- ជាគ្រូដែលយល់ច្បាស់ពីប្រធានបទ ដែលត្រូវបង្រៀនសិស្ស ហើយបង្រៀនសិស្សយ៉ាងដូចម្តេច?

៣- ជាគ្រូដែលប្រកាន់យកទំនួលខុសត្រូវក្នុងការគ្រប់គ្រងសិស្ស និង ការតាមដានវិធីសិក្សារបស់សិស្ស

៤- ជាគ្រូដែលចេះប្រើការគិតប្រកបដោយប្រព័ន្ធកម្មចំពោះការអនុវត្តរបស់គាត់ និង ចេះសិក្សាដកពិសោធពីគ្រូឯទៀត

៥- ជាសមាជិករបស់សហគមន៍សិក្សា

លទ្ធផលដែលកើតមកពីការរំខានដល់ការសិក្សាក្នុងវិស័យអប់រំរបស់សហរដ្ឋអាមេរិក ធ្វើអោយកក្រើកដល់ការងាររបស់ថ្នាក់ដឹកនាំប្រទេសជាតិដែលផ្តល់នូវការតំរង់ទិសក្នុងវិស័យអប់រំដូចតទៅ :

- បង្កើតអោយមានចលនាកែទំរង់ដ៏មានឥទ្ធិពលក្នុងការកសាងរចនាសម្ព័ន្ធអប់រំឡើងវិញ
- រៀបចំកម្មវិធីសំរាប់បណ្តុះបណ្តាលសិស្សឡើងវិញ សំដៅធ្វើអោយសិស្សស្គាល់ជីវភាពរស់នៅដោយពឹងផ្អែកលើវិស័យសេដ្ឋកិច្ច និង ឈរលើមូលដ្ឋាននៃពតិមាន ។

(នៅមានត)

បណ្ឌិត : ទាន់ វឌ្ឍសុផា

សសស

**"នរណាមិនទៅមុខ គឺថយក្រោយ"**

(Qui n'avance pas, recule)

**ភាសិតបស្ចឹមប្រទេស**




# ភាសាដែលគេប្រើប្រាស់ក្នុងអ៊ីនធើណែត

ក្នុងឆ្នាំ ២០០៣ បណ្ដាអ្នកប្រើប្រាស់អ៊ីនធើណែតទាំងឡាយ បានប្រើភាសាចំនួន តែ ១១ ប៉ុណ្ណោះ ។ ភាសាអង់គ្លេសត្រូវបានគេប្រើប្រាស់ច្រើនជាងគេ ។ ប៉ុន្តែតាមគំរោងប៉ាន់ស្មាន នៅឆ្នាំ ២០០៧ ភាសាចិននឹងត្រូវប្រើប្រាស់ច្រើនជាងភាសាអង់គ្លេសទៅទៀត ។




ប្រភព : http://www.global-reach.biz/f2/index.php3

# យកប្រេងកាតធ្វើជាស្ករ

ក្រុមហ៊ុនជប៉ុនមួយឈ្មោះគីយ៉ូវ៉ា បានទទួលជោគជ័យក្នុងការយកប្រេងកាតមកធ្វើជាស្ករក្នុងទសវត្សទី៧០ ។ ក្រុមហ៊ុននេះមានឯកទេសខាងផលិតផលដែលកើតពីប្រេងកាតតាមវិធីបិត ។ នៅពេលនោះ គេអាចយកចេញពីប្រេងកាតនូវអាមីណូអាស៊ីត(aminoacides) អាស៊ីតនុយក្លេអ៊ិក (Acides nucléiques) វីតាមីន និង ប្រូតេអ៊ីន តែពុំដែលបានជាស្ករទេ ។ នេះប្រហែលជាទៅលើកដំបូងហើយដែលគេធ្វើប្រេងកាតអោយចេញទៅជាស្ករបាន ។ ឯវិធីធ្វើងាយទេ ។ គេចិញ្ចឹមបាក់តេរីម្យ៉ាងឈ្មោះអាត្រូប៉ាក់តាប៉ារ៉ាហ្វីណឺស៍ (Arthropacta paraffineus) ក្នុងប្រេង "ប៉ារ៉ាហ្វីន" ដែលជាអនុផលរបស់ប្រេងកាត ។ បាក់តេរីនេះក៏បញ្ចេញជាតិគ្លូកូស៍ (glucose) រឺជាតិត្រេហ្វាឡូស៍ (trephalose) ដែលមានជាតិស្ករនៅក្នុងនោះ ។

# អគ្គិសនីអាចជួយអោយឈើឆាប់ផ្លែ

បច្ចេកទេសនៅសហរដ្ឋអាមេរិក បានរកឃើញវិធីបង្ខំដើមឈើអោយឆាប់ផ្លែ និង អោយផ្លែបានច្រើនដោយវិធីបញ្ជាក់អគ្គិសនី ។ វិធីបញ្ជាក់នេះ គឺគេយកអេឡិកត្រូដឈ្មោលទៅដាក់ភ្ជាប់នឹងដើមឈើ ឯអេឡិកត្រូដញីដាក់នឹងមែកឈើខាងលើ ។ ការធ្វើនេះ គឺគេធ្វើដោយទៀងទាត់តាមកំនត់ពេលជាក់លាក់ ។ រហូតដល់ពេលនេះ ក្រៅពីឆាប់ផ្លែ និង ផ្លែបានច្រើនជាងមុន ដើមឈើទាំងឡាយដែលគេបានបញ្ជាក់អគ្គិសនីឥតមានបញ្ចេញប្រតិកម្មអ្វីដែលនាំអោយយើងសំគាល់ថា មានសុខភាពអន់ថយជាងមុនឡើយ ។

<u>ចំណាំ:</u> ការប្រើប្រាស់វិធីនេះត្រូវមានការប្រុងប្រយ័ត្ន

ព្រោះមានគ្រោះថ្នាក់ដល់ជីវិត ។

ដកស្រង់ដោយ : ទិត ឃាំរ

ខេមរយានកម្មលេខ ២ ខែ វិច្ឆិកា ១៩៦៨

៰ ៰ ៰ ៰ ៰ ៰

# រថភ្លើង

មនុស្សជាតិដោយមិនគិតពីការនឿយហត់នៅក្នុងរបត់នៃការវិវត្ត បានបោះជំហានដ៏ធំធេងដែលនាំមកនូវវិឡាភាពបច្ចុប្បន្ន និង ផ្លាស់ប្ដូរសង្វាក់ជីវិតរបស់គេ នោះគឺការរកឃើញ "យក្សដែក" (រថភ្លើង) ។

ការប្រឹងប្រែងនេះ បានផ្ដើមចេញពីការលំបាករបស់គេនៅក្នុងការដឹកជញ្ជូនរបស់របរធ្ងន់ៗពីកន្លែងមួយទៅកន្លែងមួយដែលកាលដើមត្រូវប្រើមនុស្ស សត្វ រទេះអូសដោយសត្វ ហើយត្រូវបានលោកឡេអូណាដឺវ៉ាំងស៊ី (Léonard de Vinci) ជាអ្នកផ្ដួចផ្ដើមគំនិតដំបូងនៅឆ្នាំ ១៤៥២ និង ត្រូវបានកែច្នៃជាបន្តបន្ទាប់ ÷



ស៊ីយ៉ូវ៉ាណ្ណីប្រង់កា (Giovanni Branca 1571-1645) គឺជាអ្នករៀបចំដំបូងនូវម៉ាស៊ីនប្រើចំហាយ ។



ដឺនីសប៉ាប៉ាំង (១៦៤៧-១៧១៤) បានបង្កើតម៉ាស៊ីនប្រើចំហាយទឹកដោយមានស៊ីឡាំងនិងពីស្ដុងហើយបានយកទៅអនុវត្តក្នុងម៉ាស៊ីនថ្មីសំរាប់នាវាចរ



នីកូឡា ជូសែបគុយញ៉ូ (Nicola-Joseph Cugnot 1725-1804) ជាវិស្វករយោធាបានបង្កើតរទេះប្រើ



បួនដប់ឆ្នាំក្រោយមកលោករីសាទ្រីវេថិត (Richard Trewethich 1771-1833) បាន



ទ្រូវៃតថិច តាមរយៈក្រុមហ៊ុនរ៉ែបានណែនាំអោយប្រើចំហាយ ដើម្បីដឹកជញ្ជូនសំភារៈ ។ នៅឆ្នាំ ១៨៨៣ ម៉ាកសើគាំង (Marc Seguin) បានមានគំនិតយកផ្ទាំងខ្ទះរាងបំពង់ ដើម្បីបង្កើនផ្ទៃសំរាប់ការដុតកំដៅ ។



នៅឆ្នាំ ១៨៣០ រថភ្លើងបែបស្តេភេនសុន (La "fusée" des stephenson) បានបើកបរលើខ្សែពីលីវែរពូល-ម៉ាន់ចេស្តេរ (Liverpool-Manchester) ។



ស៊ក ស្តេភេនសុន ក្លាយទៅជាអ្នកមាន និង ល្បីល្បាញ បានបន្តការងារនៅរោងចក្រដែលលោកបានបង្កើត ។ បុត្ររបស់លោកឈ្មោះរ៉ូប៊ែរ (Robert) គឺជាសហការីដ៏ឆ្នើមរបស់លោក ។



ខ្សែរថភ្លើងបានធ្វើអោយមនុស្សលែងបារម្ភ ទោះជិតក្តី ទោះឆ្ងាយក្តី ។



នៅអាមេរិច ការស្ថាបនាអយស្ម័យយានជាដំបូង ត្រូវជួបការលំបាកដ៏ច្រើន ហើយជាញឹកញាប់ជនជាតិដើមបានវាយប្រហារកម្មករ និង វិស្វករ ។ អ្នកទាំងនេះត្រូវមានអាវុធជាប់នឹងខ្លួនជានិច្ចសំរាប់ការពារ ។



ខ្សែរថឆ្លងកាត់ស៊ីបេរី (Transibérien) គឺជាខ្សែនៃអយស្ម័យយានវែងជាងគេនៅលើពិភពលោក ។ វាតភ្ជាប់ពីម៉ូស្គូ (Moscou) ទៅវ្ល៉ាឌីវ៉ូស្តុក (Vladivostock) ដោយឆ្លងកាត់ដំបន់ស៊ីបេរីទាំងមូលមានប្រវែង ៩ ៤៧៦ គ.ម កាត់តាមដំបន់ដាំដុះ និង ស្តិប (Steppes) ដ៏លំបាកលំបិនក្នុងល្បឿនមធ្យម ៤៥ គ.ម ក្នុង ១ ម៉ោង ។



នៅក្រោមភ្នំ គេបានចោះឧមង្គវែងៗដែលធ្វើឱ្យរថភ្លើងឆ្លងកាត់ដោយល្បឿនយ៉ាងលឿនបំផុត ដើម្បីធ្វើកុំអោយអ្នកដំនើរពុលនឹងផ្សែង ។



នៅប្រទេសអាឡឺម៉ង់ គេបានធ្វើការពិសោធរថភ្លើងដែលបើកបរលើខ្សែដែកតែមួយ ។ ល្បឿនរបស់វានៅពេលសាកល្បងមានប្រមាណ១៨០គ.ម ក្នុង១ម៉ោង ។

(Encyclopédie pour tous L-Lidis)

ប្រែសម្រួលដោយលោក :




# ល្បិចចងចាំ

ចងចាំ គឺតួចចិត្តមិនភ្លេច ដក់ជាប់ រក្សាទុកនៅក្នុងស្មារតី ឬក្នុងការនឹកឃើញនូវអ្វីៗដែលកន្លងផុតទៅ មិនភ្លេចភ្លាំង នៅតែច្បាស់ក្នុងចិត្តជានិច្ច ។ នៅក្នុងការអប់រំ បង្រៀន និង រៀន ការដែលអាចធ្វើអោយសិក្ខាកាមចេះចាំ ចងចាំ ចាំបាននោះ គឺជាគោលបំណងចំបងបំផុត ដែលអ្នកបង្រៀនទាំងឡាយចង់បាន ។

នៅក្នុងការវិវឌ្ឍន៍របស់សង្គម ជាទូទៅមានករណីច្រើនណាស់ដែលមនុស្សទាំងឡាយគួរចងចាំ ។

បុព្វបុរសរបស់យើង លោកបានយករូបភាពងាយស្រួលបញ្ចូលខ្លឹមសារនៃការអប់រំ ទូន្មានទាំងឡាយដែលលោកចង់បាន អោយទៅដក់ជាប់ ចាំជាប់ក្នុងសតិអារម្មណ៍របស់កុលបុត្រ កុលធីតារបស់ខ្លួន ។ ដូនតាយើង លោកនៅមានវិធីសាស្ត្រផ្សេងៗទៀត ក្នុងការសំរួលដល់ការចងចាំ ដោយលោកបានប្រមូលផ្តុំជាក្រងសេចក្តី រៀបចំសង្ខេបអោយខ្លី... តែក៏ស្ថិតនៅក្រោមឥទ្ធិពលនៃកំណាព្យ កាព្យឃ្លោង ចុងជួន ណែងណង ពិរោះរណ្តំ អប់រំ ទូន្មាន ក្រើនរំលឹក អោយចេះវិភាគ ប្រៀបធៀប ពិចារណា ឬក៏បង្ហាញពីទស្សនៈផ្សេងៗ ឬដើម្បីជាការកំសាន្តសប្បាយ ។ ល្បិចចងចាំទាំងឡាយ ដែលយើងបានប្រទះឃើញកន្លងមក រួមមាន ÷

- **កំណាព្យ** : ជាកំរងពាក្យសំដី មានចាប់ចុងចួន ពិរោះរណ្តំណែងណង មានឃ្លាល្បះ និង មានកំរិតចំនួនព្យាង្គជាកំណត់ (កំណាព្យខ្មែរយើងគេរកឃើញថាមាន ៥៣បទ) ។ ឧទាហរណ៍ : (បទមេបួន)

  ទោសៈនេះខ្លាំង កំលាំងក្រៃលែង តែអោយផុសវែង គ្មានអ្វីខ្លាំងដូច ។
  ត្រូវកាត់ពីតិច ត្រូវក្តិចពីតូច ត្រូវកត់អោយរួច ផុតទោសដែលខឹង ។
  អ្នកប្រាជ្ញបុរាណ បានអោយដំណឹង មិនស្តីមិនខឹង ទើបបានខន្តី ។...

- **កំរងកែវ** : ពាក្យសំដី ចាប់ចុងចួនទំនាក់ទំនងពិរោះរណ្តំដែរ តែមិនមានកំណត់ឃ្លា ល្បះ ចំនួនព្យាង្គជាក់លាក់ទេ ។ ឧទាហរណ៍ : ក្រុងទស្សមុខមារស្ងួរវង្សពង្ស ក្រឡាអស្ចារ្យ ទ្រង់ត្រាស់ថា... ។

- **សុភាសិត** : ពាក្យពិរោះ ពាក្យត្រឹមត្រូវ ពាក្យប្រដៅល្អ សំដីដែលគេនិយាយត្រូវ ។ ឧទាហរណ៍ : ចេះពីរៀន មានពីរក ។

- **ពុទ្ធភាសិត** : ពាក្យព្រះពុទ្ធ ទ្រង់ត្រាស់សំដែងហើយ ។ ឧទាហរណ៍ : អត្តាហិ អត្តនោនាថោ (ខ្លួនទីពឹងខ្លួន) ។
- **ពាក្យទំនឹមទំនៀម** : ពាក្យដែលលោកចងជាប្រស្នា ប្រៀបផ្ទឹមទៅរកសេចក្តីណាមួយ ។ ឧទាហរណ៍ : ចិត្តជាទេវទត្ត មាត់ជាទេវតា ។
- **ពាក្យស្លោក** : ពាក្យដែលចួនរណ្តំ ពីមួយទៅមួយត១គ្នារាល់ឃ្លា ។ ឧទាហរណ៍ : ចេះមិនឈ្នះចង់ ត្រង់មិនឈ្នះទាល់ កល់មិនឈ្នះគិត ឫទ្ធិមិនឈ្នះរោគ... ។
- **ពាក្យស្លោក ឬសម្លោក** : ពាក្យរៀល ចួនរណ្តំបញ្ជាក់ពីលក្ខណៈរបស់មនុស្ស ឬសត្វពាហនៈ ។ ឧទាហរណ៍ : ជំហរសិង្ហ សំលឹងខ្លា សំលេងស្វា ភ្នែកមាន់ព្រៃ ។
- **ពាក្យល្បិច** : ដូចជាល្បិចចៅក្រម ដើម្បីងាយពិនិត្យ ពិភាក្សា រកការពិត ។ ឧទាហរណ៍ : មន្តលេន សេនបទ មណ្ឌុកជ សីហលោ ។
- **ពាក្យប្រជាប្រិយ** : ពាក្យដែលប្រជាពលរដ្ឋនិយមចូលចិត្តនិយាយលេងជាទូទៅ ។ ឧទាហរណ៍ : ១.ស្រាយចិញ្ចើម ២. សំបើមយក្ស ៣. អារក្សធំ ៤. រង់ចិត្ត ៥. អាណិតខ្លួន ៦. ស្ងួនចំណី ៧. សំដីខ្មោច ៨. អាសោចនឹកក្តើ ៩. ចង្អេរបក់ ១០. បន្តក់ទឹក... ។
- **ពាក្យអក្សរកាត់** : អ.យ.ក (អប់រំ យុវជន និង កីឡា), ស.រ.អា (សហរដ្ឋអាមេរិក)
- **ពាក្យផ្សេងៗទៀត** : (អាចនៅមានដែរឬទេ ?)

ឥឡូវសូមលោកគ្រូ អ្នកគ្រូបែរមកមើល ដោយឡែកនៅក្នុងវិស័យអប់រំរបស់យើងវិញ តើនៅក្នុងវិជ្ជាជីវៈជាអ្នកបង្រៀន មានល្បិចសំរាប់អោយសិស្សចងចាំដែរឬទេ ?

ប្រាកដជាមានមិនខ្វះ ហើយមានគុណប្រយោជន៍ខ្លាំងណាស់ ព្រោះល្បិចខ្លះបានឮតែម្តង អាចចងចាំបានមួយជីវិត ។ ខ្ញុំនៅចាំបានកាលពីនៅរៀនបឋមសិក្សា លោកគ្រូខ្ញុំពន្យល់ប្រៀបធៀបថា : "ស្មើរ" ត្រូវថែម "រ" ដើម្បីអោយវាពេញ ។ តែបើ "ស្មើ" ហើយកុំបាច់ដាក់ "រ" អី ខ្លាចវាហៀរកំពប់ ។ រូបភាពនេះ ខ្ញុំនៅចាំជាប់រហូតមក ពុំដែលសរសេរពាក្យពីរម៉ាត់នេះខុសដល់ម្តងណាឡើយ ។

ឧទាហរណ៍មួយទៀត តើពាក្យណាសរសេរ "ប" ជើង "ដ" ពាក្យណា "ផ" ជើង "ដ" ? ប្ត ឬ ផ្ត ? ។ ត្រូវចាំរូបភាពនារីម្នាក់និយាយថា : "នាងខ្ញុំប្តេជ្ញាថា នឹងប្តឹងសុំប្តូរប្តីអោយបាន!" ។ នេះចង់បញ្ជាក់ថា មានតែពាក្យបួនម៉ាត់នេះទេ (ប្តី ប្តឹង ប្តូរ ប្តេជ្ញា) ដែលសរសេរ "ប្ត" ។ ក្រៅពីនោះសរសេរ "ផ្ត" ទាំងអស់ដូចជា : ផ្តល់ ផ្តាច់ផ្តិល ផ្តួល ផ្តូច ផ្តើម ផ្តេក ផ្តោះផ្តង ។ល។

ល្បិចចងចាំនេះ ពុំមែនមានសំរាប់តែក្នុងការរៀនអក្សរ សរសេរអក្ខរាវិរុទ្ធអោយត្រឹមត្រូវនោះទេ មុខវិជ្ជាដទៃទៀតក៏មានមិនខ្វះដែរ ។ ក្នុងគណិតវិទ្យាជាដើម ដូចជារបៀបគំឡើងការេអោយចំនួនណាមួយដែលមានលេខប្រាំនៅខាងចុង គឺត្រូវយកលេខខាងដើម គុណនឹងខ្លួនវាបូកមួយ រួចថែមលេខ ២៥ ពីខាងក្រោយ ។

ឧទាហរណ៍ : ចំនួន ៣៥ ។ យក ៣ x (៣+១) = ១២ ថែមលេខ ២៥ ពីក្រោយ យើងឃើញ = ១២២៥

សាកមើលម្ដងទៀត = ចំនួន ១០៥ ។

យក ១០ x (១០+១) = ១១០ ថែមលេខ ២៥ ពីក្រោយ យើងបាន = ១១០២៥

នៅក្នុងភូមិវិទ្យា ដើម្បីគូសផែនទីប្រទេសកម្ពុជា គេត្រូវគូសចតុកោណកែងដែលមានបណ្ដោយ និង ទទឹង ប៉ុន្មានការេ ហើយចាប់គូសពីណាទៅណា កាត់តាមត្រង់ណាជាដើម ។ រូបវិទ្យា ឬមុខវិជ្ជាផ្សេងៗទៀត ក៏អាចមាន ល្បិចចងចាំដែរ ។

ក្នុងការរៀនភាសាបារាំង ក៏មានល្បិចចងចាំដូចតែគ្នា ឧទាហរណ៍ ការសរសេរពាក្យ tout, tous ឬ toux ? តើត្រូវដាក់ t, s ឬ x ខាងចុង ? ។ សិស្សជំនាន់មុន (សម័យរៀនបារាំងច្រើន) សូត្រចាំមាត់ថា :

Tou le, tou "t" (tout)
Tou les, tou "s" (tous)
tou ខ្វះៗ tou "x" (toux)

ឬក៏ដូចជាពាក្យ discuter និង disputer ធ្វើម៉េចដើម្បីចាំថា ពាក្យណាប្រែថា "ជជែកគ្នា" ពាក្យណាថា "ទាស់ទែងគ្នា" ? គេត្រូវចំណាំ តាមអក្ខរក្រមបារាំង គឺអក្សរ C នៅមុនអក្សរ P ស្របនឹងន័យថា ជជែកគ្នា រួចទើបទាស់ទែងគ្នាដូច្នេះ :

discuter (អក្សរ C) = ជជែកគ្នា

disputer (អក្សរ P) = ទាស់ទែងគ្នា

ខាងលើនេះ គ្រាន់តែជាឧទាហរណ៍ខ្លះៗនៃល្បិចចងចាំដែលខ្ញុំជឿជាក់ថា នៅមានច្រើនទៀតតាមមុខវិជ្ជាផ្សេងៗ តិចក្ដី ច្រើនក្ដី គ្រាន់តែពុំទាន់មាននរណាប្រមែប្រមូល រៀបចំចងក្រងអោយបានទៅជាក្បួន ជាច្បាប់សំរាប់ជាជំនួយស្មារតីដល់សិស្សានុសិស្សយើងនៅឡើយ ។ ពិតណាស់ហើយថា មនុស្សម្នាក់ៗពុំមែនមានសតិស្មារតីការចងចាំដូចគ្នានោះទេ តែបើមានល្បិចជាជំនួយ អាចជួយដល់ការសិក្សាមួយចំណែកណានោះដែរ ។

តើគួរឬទេ សាកល្បងប្រមូលផ្ដុំល្បិចចងចាំទាំងឡាយទៅតាមមុខវិជ្ជានីមួយ ដើម្បីបានជាជំនួយដល់ការរៀនសូត្ររបស់សិស្សានុសិស្សយើង ? ។

លោក : **យស់ អ៊ាង**

---

"ខ្ញុំឮ - ខ្ញុំភ្លេច
ខ្ញុំឃើញ - ខ្ញុំចាំ
ខ្ញុំធ្វើ - ខ្ញុំយល់" ៗ

ប៉ូល អូប្រីយ៉ង់ អ្នកអប់រំសិទ្ធិមនុស្ស

# គណិតវិទ្យា

## ត្រីកោណ

- ថ្នាក់ទី ៦
- មេរៀនទី ១១
- សៀវភៅសិស្ស ទំព័រ ១១៧-១១៩

**អត្ថបទជំនួយ:**

* ចូរបង្កើតចំនោទមួយសមស្របនឹងគំនូរបំព្រួញនេះ រួចដោះស្រាយ ។




ប្រធាន.............................................................

.............................................................

.............................................................

ដំណោះស្រាយ.............................................................

.............................................................

.............................................................

ផ្អែកលើគំនូរបំព្រួញនេះ អ្នកគ្រូ លោកគ្រូអាចណែនាំអោយសិស្សកសាងប្រធានចំនោទបានច្រើន ។ នោះជាឧទាហរណ៍មួយ :

ចំការមួយរាងត្រីកោណ មានជ្រុងមួយប្រវែង ២១ម ជ្រុងមួយទៀតប្រវែង ១៧ម និង ជ្រុងមួយទៀតប្រវែង ១៨ម ។ នៅលើជ្រុង ២១ម គេធ្វើទ្វារមួយមានចន្លោះ ៣ម និង ជ្រុង ១៨ម មានទ្វារចន្លោះ ២ម និង ធ្វើរបងព័ទ្ធជុំវិញចំនួន ៥ខ្សែ ។

សួរថា តើគេព័ទ្ធជុំវិញចំការអស់លួសប៉ុន្មានម៉ែត្រ ?

**ចំលើយ:**

បរិវេណចំការ :

២១ម + ១៨ម + ១៧ម = ៥៦ម

បរិវេណដែលត្រូវព័ទ្ធលួស :

៥៦ម - (៣ម + ២ម) = ៥១ម

ប្រវែងលួសសំរាប់ព័ទ្ធរបងចំការ :

៥១ X ៥ = ២៥៥ម

លោកស្រី : **កែវ សុច្ចរិទ្ធ** សាស្ត្រាចារ្យ

នៅមហាវិទ្យាល័យគរុកោសល្យ

# គំនូរ

## វិធីបង្រៀនគំនូរ (ត)

ដោយលោក : ចាន់ ត្រា

### ពណ៌

ដើម្បីអោយគំនូរប្រកបទៅដោយការជាក់ស្ដែងពិតៗ និង អោយរឹតតែមានសោភ័ណភាពខ្លាំងឡើងទៀតនោះ ត្រូវណែនាំសិស្សអោយស្គាល់ និង ប្រើពណ៌ ដើម្បីលាបគំនូរទៅតាមពណ៌ធម្មជាតិពិតៗ លើគំនូរជារូបភាព និង លាបរំលេចក្នុងផ្ទាំងតុបតែងលំអ ។

ពណ៌ដែលត្រូវអោយសិស្សរៀនប្រើជាដំបូងនេះ គឺខ្មៅដៃពណ៌ ក្រមួនពណ៌...ល... ។

មុនអោយសិស្សប្រើពណ៌ ត្រូវនាំសិស្សអោយស្គាល់ច្បាស់នូវឈ្មោះពណ៌នីមួយៗជាមុនសិន ដោយយកពណ៌ទាំងនោះមកបង្ហាញអោយបានជាក់ស្ដែងនឹងភ្នែក ។

ជាបឋម ពណ៌ដែលសិស្សត្រូវស្គាល់មានដូចខាងក្រោមនេះគឺ ពណ៌ស្វាយ ខៀវចាស់ ខៀវខ្ចី បៃតងចាស់ បៃតងខ្ចី លឿងចាស់ លឿងខ្ចី ក្រហមចាស់ ក្រហមខ្ចី និង ពណ៌ដីលែង( ពណ៌ដែលបានរាប់រៀបខាងលើនេះមានគ្រប់ទាំងអស់ក្នុងប្រអប់ខ្មៅដៃពណ៌នីមួយៗ) ។

នៅថ្នាក់ទី ២ នេះ សិស្សទើបនឹងចាប់ប្រើពណ៌ជាលើកដំបូងគឺ ខ្មៅដៃពណ៌ ឬក្រមួនពណ៌ ដើម្បីគូសដាក់បំពេញក្នុងគំនូរជារូបភាព និង ដាក់រំលេចក្នុងផ្ទាំងតុបតែងលំអអោយត្រូវទៅតាមពណ៌ធម្មជាតិ និង ប្រកបទៅដោយសោភ័ណភាព ។

គំនូរដាក់ពណ៌នេះ ត្រូវអោយសិស្សគូរអ្វីៗដែលត្រូវដាក់ជាប្រធាននោះ នៅលើផ្ទៃក្រដាសដែលមានរាងជាចតុកោណកែង ដាក់បញ្ឈរ ឬផ្ដេកទៅតាមរាងរៅអ្វីៗដែលត្រូវគូរ ។



*ឧទាហរណ៍ :* ១- ផ្កាឈូករ័ត្ន

២- ទាហែលទឹក

ផ្កាឈូករ័ត្ននេះត្រូវគូរលើផ្ទៃក្រដាសចតុកោណកែងបញ្ឈរ ពីព្រោះផ្កាឈូករ័ត្ននេះមានជំហរខ្ពស់ទៅលើ ។



ទាហែលទឹកត្រូវគូរនៅលើផ្ទៃចតុកោណកែងផ្ដេក ពីព្រោះរូបទានេះមានរាងរៅសណ្ដូកវែងទៅខាង ។

បានជាអោយសិស្សគូររូបភាពផ្សេងៗ ក្នុងផ្ទៃក្រដាសរាងចតុកោណកែងដូចនេះ ដើម្បីជាទំលាប់មួយអោយសិស្សក្រោយអំពីដាក់ពណ៌គំនូររូបភាពជាប្រធាន ច្នៃរិះរកពណ៌ដទៃទៀតមកដាក់បំពេញផ្ទៃចតុកោណកែងនៅសល់នោះជាប់ាន ដើម្បីអោយគំនូរជាប្រធានលេចច្បាស់ឡើង( របៀបគំនូរលាបពណ៌) ។

**<u>របៀបគូរ</u>**

ដើម្បីអោយលោកគ្រូ អ្នកគ្រូយល់ហើយអាចដឹកនាំសិស្សអោយគូរបាននូវផ្ទាំងគំនូរជារូបភាពផ្សេងៗនោះ យើងជូនរបៀបចែកជាវគ្គ ដើម្បីជាឧទាហរណ៍ដូចខាងក្រោមនេះ ។

ប្រធាន : ផ្កាមួយទង



**<u>សំភារៈ</u>**

- ក្រដាស ទំហំ ៨ x ១២ ស.ម
- ខ្មៅដៃខ្មៅ
- ខ្មៅដៃពណ៌ ឬក្រមួនពណ៌មួយប្រអប់

**<u>របៀបគូរ</u>**

១- គូសបន្ទាត់សូន្យបញ្ឈរចែកផ្ទាំងក្រដាសចតុកោណជា ២ ភាគស្មើ ។

២- ចែកបណ្តោយចតុកោណកែងនោះជា ៣ ភាគស្មើ ហើយគូសបន្ទាត់ពីចំណុចទាំងពីរនោះទៅភ្ជាប់នឹងចំណុចនៃបណ្តោយចតុកោណម្ខាងទៀត ( បានជាផ្ទៃការេតូចៗ ៦)( រូបទី ១) ។

៣- គូរបណ្តូល ឬបេះដូងផ្កាជារង្វង់មូលចំកណ្តាលបន្ទាត់ខ្វែងខាងលើ ( រូបទី ២) ។

៤- គូសរង្វង់មូលធំមួយទៀតព័ទ្ធជុំវិញបណ្តូល ឬបេះដូងផ្កា និង គូរទងភ្ជាប់ពីផ្កាចុះសណ្តូកតាមបន្ទាត់សូន្យមកទល់នឹងចតុកោណកែងខាងក្រោម ( រូបទី ៣) ។

៥- គូរស្រទាប់ផ្កា និង ស្លឹក ( រូបទី ៤) ។

**<u>ការដាក់ពណ៌</u>**

១- បណ្តូល ឬបេះដូងផ្កា ( ពណ៌លឿងទុំ) ។

២- ស្រទាប់ផ្កា ( ពណ៌ក្រហមខ្ចី ឬពណ៌លឿងខ្ចី) ។

៣- ស្លឹកចំហៀងខាងលើ ( ពណ៌បៃតងចាស់) ចំហៀងខាងក្រោម ( ពណ៌បៃតងខ្ចី) ( រូបទី ៥) ។

៤- ផ្ទៃ ( ពណ៌ខ្មៅ ឬខៀវចាស់) ដោយមានទុកខ្សែសជុំវិញរូបភាព ( រូបទី ៦) ។




ប្រធាន : ទាហែលទឹក

- ក្រដាសទំហំ ៨ x ១២ ស.ម
- ខ្មៅដៃខ្មៅ
- ខ្មៅដៃពណ៌ ឬក្រមួនពណ៌មួយប្រអប់

__របៀបគូរ__

១- គូសបន្ទាត់សូន្យពុះកាត់បណ្ដោយចតុកោណកែងជា ២ ភាគស្មើ ។

២- គូសបន្ទាត់សូន្យពុះកាត់ទទឹងចតុកោណកែងជា ២ ភាគស្មើទៀត (បានជាចតុកោណកែងតូច ៤ ទំហំស្មើគ្នា) (រូបទី ១) ។

៣- គូសបន្ទាត់សូន្យពុះកាត់ចតុកោណកែងតូចទាំង ៤ ។

៤- គូសបន្ទាត់សូន្យពុះកាត់ចំកណ្ដាលបណ្ដោយចតុកោណកែងតូចៗទាំង ៤ នោះទៀត ។

៥- នៅក្នុងចតុកោណកែងឋិតនៅចំកណ្ដាលខាងក្រោម គឺចតុកោណកែង កខគឃ គូសរង្វង់មូលទ្រវែងសណ្ឋានជាពងទាមួយ ហើយគូសរង្វង់មូលតូចមួយទៀត ចំកណ្ដាលចតុកោណកែងខាងលើ និង ខាងឆ្វេង (រូបទី ៣) ។

៦- គូសគំនូសកោងពីរ ភ្ជាប់រង្វង់មូលតូចខាងលើមកនឹងរង្វង់មូលទ្រវែងខាងក្រោម (កទា) ។ នៅចុងខាងស្ដាំរង្វង់មូលទ្រវែងនោះត្រូវគូរកន្ទុយ (រូបទី ៤) ។

៧- គូរចំពុះ ភ្នែក ស្លាប និង គូរផ្ទៃទឹកជារលក (រូបទី ៥) ។

__របៀបដាក់ពណ៌__

១- មេឃ (ខៀវខ្ចី)(ខៀវលាយសច្រើន) ។

២- ផ្ទៃទឹករលក (ខៀវ) គូរអង្កាញ់រលកពណ៌ខៀវចាស់ ។

៣- ចំពុះ (លឿងទុំ) ។

៤- កទា (បៃតងចាស់) ។

៥- ចុងស្លាប និង ចុងកន្ទុយ (បៃតងចាស់)

xxxxxx

# ភូមិវិទ្យា

## តំបន់អាកាសធាតុ និង ប្រជាជន

- ថ្នាក់ទី ៥
- មេរៀនទី ២០
- សៀវភៅសិស្សទំព័រទី ២៣-២៤
- សៀវភៅគ្រូ ទំព័រទី ៥២

<u>អត្ថបទជំនួយ:</u>

### យកឈ្មោះតាមអ្នករកឃើញ

### សែលស៊ីយូស និង ហ្វារេនហៃត៍ (Celsius et Fahreinheit)

នៅតាមបណ្ដាប្រទេសដែលប្រើប្រព័ន្ធមេទ្រិក (système métrique) គេប្រើរង្វាស់កំដៅជាអង្សាសែលស៊ីយូស($^{o}C$) ។ រីឯបណ្ដាប្រទេសអង់គ្លោសាក់សុង(anglo-saxon)វិញ គេនិយមប្រើប្រាស់អង្សាហ្វារេនហៃត៍ ($^{o}F$) ។

តើហេតុដូចម្ដេចបានជាប្រព័ន្ធពីរខុសប្លែកគ្នាដូច្នេះ អាចមានវត្តមានរួមជាមួយគ្នាក្នុងពិភពលោកដែលគេចង់អោយក្លាយជា "ភូមិភព" តែមួយ បានយូរអង្វែងបែបនេះ ។

គឺដោយសារថា ការគិតគូរលំអិតច្បាស់លាស់ក្នុងការវាស់កំដៅនេះ ក៏ដូចជាការរកឃើញធំៗទាំងឡាយទៀតដែរ បានកើតមានឡើងនៅតាមប្រទេសផ្សេងៗគ្នា តែក្នុងសម័យកាលមួយប្រហាក់ប្រហែលគ្នា ។

រូបវិទូអាល្លឺម៉ង់គឺលោក Daniel Fahreinheit នៅដើមសតវត្សទី ១៨ បានបង្កើតសីតុណ្ហមាត្រដំបូងគេបង្អស់ដោយប្រើបារត ។ គាត់រកឃើញកំរិតសីតុណ្ហភាពដែលធ្វើអោយបារតកករឹង និង ធ្វើអោយបារតពុះ រួចគាត់ចែកចន្លោះនៃចំណុចទាំងពីរជា ៩៦ ចំណែក ។ រង្វាស់នេះត្រូវបានជនជាតិអង់គ្លេសទទួលប្រើប្រាស់មុនគេ បន្ទាប់មកពួកអាមេរិកខាងជើង និង អូស្ត្រាលី ។ ប៉ុន្មានឆ្នាំក្រោយមក តារាវិទូស៊ុយអែតម្នាក់ គឺលោកAnders Celsius ដោយជាប់ចិត្តនឹងរូបវិទ្យាជាខ្លាំង លោករៀបចំបង្កើតបានសីតុណ្ហមាត្រមួយបែបទៀត ដោយប្រើបារតដូចគ្នានៅឆ្នាំ ១៧៤១ ។ លោកបានក្រិតដាក់លេខ 0 នៅចំណុចដែលទឹកពុះ និង ដាក់លេខ ១០០ នៅចំណុចដែលទឹកកក ។ នៅពេលជាមួយគ្នានោះ អ្នកប្រាជ្ញបារាំងម្នាក់ក៏បានរកឃើញប្រព័ន្ធរីកមាឌ និង រួមមាឌរបស់បារតដូចគ្នាដែរ តែលោកកំណត់បញ្ច្រាស់មកវិញ គឺលេខ 0 នៅពេលទឹកកក និង លេខ ១០០ នៅពេលទឹកពុះ ។ លុះមកដល់សម័យដែលបារាំងធ្វើបដិវត្តន៏កសាងប្រព័ន្ធមេទ្រិក គេបានកំណត់ការវាស់កំដៅមួយកំរិតដែលមានមួយភាគរយនៃប្រវែងចន្លោះពីចំណុចទឹកពុះទៅទឹកកក ថាមួយដឺក្រេសង់ទីក្រាត (degré centigrade) ។ ទើបតែនៅឆ្នាំ ១៩៤៨ កងសន្និសីទពិភពលោកស្ដីពីទំងន់ និង រង្វាស់មាត្រទេដែលគេបានកំណត់ឈ្មោះជាផ្លូវការថា ដឺក្រេសែលស៊ីយូស

(degré Celsius) នោះ ។

**កំណត់សំគាល់ដើម្បីចាយចាំ :**

- សីតុណ្ហមាត្រទាំងពីរបែប ប្រើប្រព័ន្ធរីក និង រួមមាឌរបស់បារត ។
- សីតុណ្ហមាត្រ Fahreinheit គិតតាមបារតកកទៅបារតពុះ គឺពី 0°F ទៅ 96°F ។
- សីតុណ្ហមាត្រ Celsius គិតតាមទឹកកកទៅទឹកពុះ គឺពី 0°C ទៅ 100°C ។
- បើយកសីតុណ្ហមាត្រ Fahreinheit មកក្រិតតាមទឹកកកទៅទឹកពុះនោះ មាន ១៨០ ក្រិត ។ គឺថា បើយកសីតុណ្ហមាត្រនេះមកវាស់ទឹកកកឃើញ 32°F និង វាស់ទឹកពុះឃើញ 212°F ។






## ច្បាប់ពាក្យចាស់

(បទព្រហ្មគីតិ)

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។
ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្គរទឹកឃ្មុំ ពូនសំងំឆីម្នាក់ឯង ។
បានហើយចង់បានទៀត ឆ្អៀតហើយឆ្អៀតពុំគិតឈ្វេង មើលយល់តែម្នាក់ឯង មិនយល់គេឯទៀតផង ។
នឹងស៊ីចង់ពិសា ខ្ជិលទំពាឱ្យហ្មត់ហ្មង យល់នាមថាជាមង យល់ឯជង់ថាជាកួយ ។
យល់តាថាជីដូន យល់ឯកូនថាជាក្មួយ យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។
យល់ទោសថាជាគុណ យល់ឯបុណ្យថានរក យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។
ស្លៀកស្បង់មិនកោរសក់ ឆ្នុះកញ្ចក់ធ្មេចនេត្រា យល់សេះថាជាលា យល់គជាថាកណ្ដុរ ។

.......................................................................................................................

.......................................................................................................................

អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។
អ្នកខ្ពស់រក្សាទាប ដោយសភាពធមិបុរាណ អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្អារ ។
រក្សាទៅមុខរឹង ឥតកំដឹងអស់អម្បាល ចំណោរចិរកាន់កាល ដូចរបងស្រោស់បន្លា ។
កុំឆ្អែតពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា គេឃ្លានៗផ្ទៃផ្សា ឱ្យស៊ីរ៉ាបានឆ្អែតផង ។

.......................................................................................................................

.......................................................................................................................

ដកស្រង់ដោយ : ទិវ យ៉ារ

# ព្រះគុណម៉ែ

(បទពាក្យ ៧)

កូនអើយចូរអ្នកត្រងត្រាប់ស្ដាប់ ម្ដាយនឹងសារស័ព្ទសព្វសេចក្ដី
អោយកូនបានយល់ទាំងប្រុសស្រី ដឹងទេថាអ្វីជាគុណម៉ែ ។
ពរពោះកូនស្ងួនកន្លងមក គំរប់រាប់យកប្រាំបួនខែ
ម៉ែចាញ់ស្ដាំងស្ដមក្អួតឥតល្ហែ កំលាំងប្រួលប្រែបាយមិនបាន ។
ម៉ែតែងគេងគិតព្រួយបារម្ភ ក្នុងចិត្តរណ្ដំឥតស្រាកស្រាន្ដ
លុះគំរប់ថ្ងៃកើតកល្យាណ ដឹងទេភ័ពផានតើយ៉ាងណា? ។
ពាក្យដែលគេថាឆ្លងទន្លេ កូនស្ដាប់មាសមេហើយដឹងថា
ទន្លេធំណាស់ណាំកូនណាំ ប្រដូចមាតាកើតរូបថ្លៃ ។
បើអ្នកឆ្លងរួចទើបម៉ែផុត ជីវិតគត់មត់ថៃចរណៃ
បើឆ្លងមិនផុតជីវិតក្ស័យ ចោលរូបកូនថ្លៃអោយកំព្រា ។
ឥឡូវរូបកូនធំដឹងក្ដី ម្ដេចក៏ហេតុអ្វីមិនមេត្តា
ធ្វើបាបចិត្តម្ដាយអោយឈឺផ្សា ព្រោះតែរូបបាមិនខំរៀន ។
កូនគិតពីដើរលេងស៊ីចាយ មិត្តភក្ដិសប្បាយខុសរបៀន
កូនសេពសុរាសេពគ្រឿងញៀន នាំទុក្ខទន្រ្ទានដល់រាងកាយ ។
រូបកូនខុសប្លែកក្មេងធម្មតា សាច់ឈាមស្រស់ថ្លាបែរប្រែក្លាយ
ទៅជាស្លេកស្លាំងនាំអន្ដរាយ សុខភាពរាងកាយស្រកផ្ទួនៗ ។
ទំរាំដល់កូនភ្ញាក់ស្មារតី រូបម្ដាយក្សិណក្ស័យហើយមាសស្ងួន
ទោះកូនទ្រហោយំបោកខ្លួន អ្នកម្ដាយនឹមនួនមិនលឺឡើយ ។
ម៉ែអើយៗម៉ែរស់វិញមក កូនប្រុសពន្លកដឹងខុសហើយ
កូនសុខចិត្តស្លាប់មិនស្ដាយឡើយ ឱ្យតែម៉ែអើយរស់ឡើងវិញ ។
កូនស្ដាយខ្លាំងណាស់កំហុសឆ្គង នាំអោយសៅហ្មងទុក្ខទោរម្នេញ
ម៉ែឈឺចុកចាប់ស្ដីមិនចេញ ស្លាប់គ្មានវិលវិញចោលកូនហើយ ។
ពេលបាត់រូបអ្នកទើបកូនដឹង កូនគ្មានទីពឹងអ្នកណាឡើយ
មានតែអ្នកទេអ្នកម្ដាយអើយ កូនស្រែកខុសហើយមួយជីវិត ។
គុណម៉ែធំណាស់ធំប៉ុនភ្នំ មាសប៉ុនដូងទុំមិនស្មើពិត
កូនប្រុសកូនស្រីត្រូវតែគិត កសាងជីវិតសងគុណម៉ែ ។

អ្នកគ្រូ **ពៅ ចូរ៉ាវី** អនុវិទ្យាល័យចតុមុខ

# នំខ្មែរ

(បទកាកគតិ)

នំខ្មែរល្អឯក គ្មានអ្នកប្រកែក ថាឥតខ្លឹមសារ ព្រោះជាស្នាដៃ
តាំងពីដូនតា បវរថ្លៃថ្លា បន្សល់ទុកអោយ ។
នំខ្មែរច្រើនមុខ ចូរអ្នកចាំទុក កុំបីកន្តើយ នំជាលនំចាំង
រសឆ្ងាញ់ឥតស្បើយ នំគមមិនលាយ គ្រឿងក្រូចអន្សម ។
នំខ្មែរប្រើម្សៅ ដំណើបសខ្មៅ សក្តិសមទំនង អង្ករកិនថ្មី
គ្មានមេរោគផង ប្រជាប្អូនបង និយមពិសា ។
នំខ្មែរខ្ចប់ស្លឹក ចំនងរុំរឹត គ្មានធ្លាយត្រង់ណា ស្មោះ រឹចំបុយ
អោយបានស្រេចការ ឆ្អិនល្អកាលណា ភ្ញៀវមើលតាមចិត្ត ។
នំខ្មែរងាយធ្វើ ស្រុះគ្នាអើពើ មូលមាត់គំនិត គ្រឿងផ្សំងាយរក
មានស្ករត្នោតស្អិត ខ្ទិះដូងឈ្ងុយពិត ម្រេចសណ្តែកបាយ ។
នំខ្មែរពិសេស ពិសាម៉ោងនេះ អារម្មណ៍សប្បាយ ឆាប់មានកំលាំង
សព្វសព៌ាង្គកាយ រោគាទាំងឡាយ មិនអាចញាំញី ។
នំខ្មែរសុទ្ធល្អ ប្រសើរបវរ គ្មានជាតិគីមី មិនបាច់ច្រកថង់
ព្យួរលក់មួលមីរ ទុករាប់ឆ្នាំខែ មិនផ្អូមនោះឡើយ ។
នំខ្មែរគ្មានទោស គ្មានផ្តល់កំហុស មិនដឹងកោះត្រើយ ដូចនំចិនយួន
តែបើល្មោភហើយ មុខជាថ្ងៃក្រោយ ប្រែរជាពុកធ្មេញ ។
នំខ្មែរថ្លៃថ្លា ប្រសើរក្រៃណា សូមកុំទោមេញ បើយកទៅជូន
ចាស់ទុំនោះមិញ គាត់អោយពរពេញ បានមគ្គបានផល ។
នំខ្មែរមានន័យ បុណ្យទានការក្តី ញាតិជួយរវល់ រៀចស្មោះចំអិន
ស្រង់រៀបតំកល់ ទុកចែកចាយផ្តល់ ទៅតាមការគួរ ។
នំខ្មែររក្សា មតិកដូនតា មានតាំងពីយូរ ស្លូមនាំគ្នាស្ទួយ
កុំអោយអាប់អួរ រួមគ្នាគិតគូរ ប្រយ័ត្នបាត់បង់ ។
នំខ្មែរក្រើល្បី ទោះក្រុងស្រែក្តី នៅផ្គេតអារម្មណ៍ និយមពិសា
ដាក់លក់របាំង តាមរែស្រែក្រុងខ្ទង់ ទឹកមុខប្រិមប្រិយ ។

លោកគ្រូ : ឆេង សុផល
បឋមសិក្សាកំរ៉ែង ខេត្តព្រៃវែង

# ការច្នៃប្រឌិត

១. រវាងចំនុច ៤ តើគេអាចបង្កើតអ្វីបានខ្លះ ? (*)

ចំលើយ :

- អ្នកច្បាស់ជាចាប់គូសជារាងរេខាគណិត



- ចាប់ពីពេលនេះ អ្នកហ៊ានគូសជារង្វង់មូល



- ចេញពីក្របខណ្ឌនេះ អាចគូសវេះវាងជាអ្វីផ្សេង



២. ផ្កាកូលាប ៣ទង និង កំរងផ្កាម្លិះ ៤ តើអាចបង្កើតអ្វីបាន ?

ចំលើយ ÷

ប្រសិនបើអ្នកជាអ្នកប្រាដកនិយម
- ផ្កា ៧ ដុំ
- ថ្លៃ ១៥០០៛

ប្រសិនបើអ្នកជាអ្នកមនោនិយម
- ផ្កាមួយបាច់
- ជំនូន (Cadeau) ស្រស់ស្អាត

ប្រសិនបើអ្នកជាវិចិត្រករ
- គ្រឿងតែងលំអ
- ផ្ទាំងលំអ

ប្រសិនបើ..........................................................................................

**កែវ យ៉ារ**

---

* តាមរយៈការច្នៃប្រឌិត គេអាចវាយតំលៃអ្នកច្នៃប្រឌិតបាន



# សមាសនាម

**និយមន័យ:**

នាមដែលគួបគ្នាពីរពាក្យ រឺច្រើនពាក្យជានាមមួយហៅថាសមាសនាម ។ ពាក្យខ្មែរដែលគួបផ្សំចូលគ្នានោះ អាចមានន័យមួយផ្សេង មិនមែនដូចន័យដើមនោះទេ ។ ឧទាហរណ៍ : ដីស ខ្មៅដៃ ដើមឈើទាល-ល- ព្រោះថា ដីសមានដី ស ក្រហម ខៀវ ខ្មៅដៃ ក៏ដូចនោះដែរ ។

<u>ការបង្កើតសមាសនាម :</u>

សមាសនាមជានាមគួបគ្នាដោយ :

- នាម និង នាម : ឧទាហរណ៍ : ដង្កូវនាង សំណែកបាយ ជនានុជន ទេវិន្ទ ...
- នាម និង គុណនាម : ឧទាហរណ៍ : ដីស គ្រប់ស្រូយ ឈើទាល លោកធំ...
- នាម និង កិរិយាសព្ទ : ឧទាហរណ៍ : គ្រូបង្រៀន តុសរសេរ ពុទ្ធានុញ្ញាត...
- កិរិយាសព្ទ និង កិរិយាសព្ទ : ឧទាហរណ៍ : សរសេរតាមអាន...

ក្នុងភាសាខ្មែរ មានពាក្យខ្មែរ និង ពាក្យបាលី ។ រីឯរូបភាពនៃការធ្វើសមាសនោះក៏មានការខុសប្លែកគ្នាដែរ:

ក- <u>ភាសាខ្មែរ</u> : មានភាពងាយស្រួល រលូនទៅតាមលំដាប់ពាក្យដែលគេចង់គួបនោះ ឧទាហរណ៍ : ដី + ស > ដីស, សំណែក + បាយ > សំណែកបាយ... ។

ខ- <u>ភាសាបាលី</u> : បើកាលណាពាក្យដែលយកមកភ្ជាប់ជាពាក្យកើតឡើងអំពី :

- តួព្យញ្ជនៈ : ប្រកបខាងចុង និង ពាក្យផ្ដើមពីព្យញ្ជនៈដែរ នោះគេត្រូតព្យញ្ជនៈដើមនៃពាក្យយកមកគួប : ឧទាហរណ៍ : ពុទ្ធ + បញ្ញត្តិ > ពុទ្ធប្បញ្ញត្តិ, អនេក + បការ > អនេកប្បការ, បទ + បញ្ញត្តិ > បទប្បញ្ញត្តិ, អវសាន + បញ្ញត្តិ > អវសានប្បញ្ញត្តិ... ។
- ស្រះពេញតួ : ស្រះនោះត្រូវផ្លាស់ជាស្រះនិស្ស័យវិញ ឧទាហរណ៍ : គជ + ឥន្ទ្រ > គជេន្ទ្រ, ជន + អធិបតី > ជនាធិបតី...។
- ស្រះខាងចុងនៃពាក្យ និង ពាក្យភ្ជាប់ផ្ដើមដោយស្រះពេញតួ នោះគេចុះថែមអាគមត្រង់

ចន្លោះកណ្តាល ឧទាហរណ៍ : ចតុ + អង្គ > ចតុ + រ + អង្គ > ចតុរង្គ, ចតុ +អរិយសច្ច > ចតុរារីយសច្ច, បរិ + ឱសាន > បរិ + យ + ឱសាន > បរិយោសាន, អ + អត្ត > អនត្ត, អ + ឯក > អនេក, អ + អន្ត > អនន្ត, អ + អាគត > អនាគត ...ល...

**<u>សង្ខេប:</u>** សមាសនាមបាលីដែលយកមកប្រើប្រាស់ជាភាសាខ្មែរ ជាទូទៅក៏មានការសរសេរបែបទំលាប់ដូចជាភាសាខ្មែរដែរដូចជា : ពុទ្ធបញ្ញត្តិ, រាជបញ្ញត្តិ, នាមបញ្ញត្តិ, ចតុមុខ, ចតុលោកបាល -ល-។ (វចនានុក្រម ជួន ណាត គ.ស.១៩៦៧) ។

ដូចនេះគួរយើងសរសេរសំរបសំរួលទៅតាមភាសាខ្មែរវិញ ក៏ជាការមួយប្រសើរដែរ ព្រោះងាយស្រួលទាំងការសរសេរ ទាំងការអាន : ពុទ្ធ + បញ្ញត្តិ > ពុទ្ធ បញ្ញត្តិ( ពុត + បញ្ញាត់) ≠ ពុទ្ធប្បញ្ញត្តិ( ពុត + ធាប់ + បញ្ញាត់។

ក្នុងករណីសំរបសំរួលនេះ យើងបានអនុវត្តច្រើនប្រការមកហើយ ជាក់ស្តែង[១] ដូចជា "ជន" :

- ជន ( ជ:ន: ) > ជន ( ជន់)( យកព្យញ្ជនៈចុងធ្វើជាព្យញ្ជនៈប្រកប)
- ចោរ ( ចោរ: ) > ចោរ ( ចោរ)( អានបំបាត់ចោលព្យញ្ជនៈចុងដោយមិនប្រើទណ្ឌឃាត)
- ប្រយោជន( ប្រ:យោជ:ន: ) > ប្រយោជន៍( ប្រយោ៉ច)( អានបំបាត់តួព្យញ្ជនៈចុង ១ តួដោយប្រើទណ្ឌឃាត)
- វិបត្តិ (វិប័តតិ) > វិបត្តិ (វិប័ត)( អានបំបាត់ស្រៈ និង ព្យញ្ជនៈចុងព្យាង្គ
- ភេទ ( ភេទ: ) > ភេទ៍ ( ភេ)( អានបំបាត់ស្រៈ និង ព្យញ្ជនៈចុងព្យាង្គដោយប្រើទណ្ឌឃាត)
- អាទិ ( អាទិ) > អាទិ៍ ( អាត)( អានបំបាត់ស្រៈចុងព្យាង្គទុកតួព្យញ្ជនៈដោយប្រើទណ្ឌឃាត)
- ឧបករណ៍ (ឧប:ក:រ:ណ:) > ឧបករណ៍ (អ៊ុប:ក)( អានបំបាត់ព្យញ្ជនៈចុងព្យាង្គ ២ តួ និងស្រៈដោយគ្រាន់តែប្រើទណ្ឌឃាតប៉ុណ្ណោះឯង)
- បរលោក (ប៉:រ:លោក:) > បរលោក (ប-ឡោក)( អានបំបាត់តួព្យញ្ជនៈដែលនៅកណ្តាលពាក្យ)
- សកលលោក ( ស:ក:ល:លោក: ) > សកលលោក ( សកល់លោក)( អានប្រកបព្យាង្គកណ្តាល)
- ........................................................................................................

លោក : **ម៉ុម សូម៉ាច**

បណ្ណារក្សនៅមហាវិទ្យាល័យគរុកោសល្យ

(ប្រភព : វេយ្យាករណ៍ ពៅ អ៊ុំ)

xxx ✲ xxx

(១) ធ្វើពាក្យបាលីអោយជាពាក្យខ្មែរ ទស្សនាវដ្តីអប់រំ លេខ ២២




# តើលោកគ្រូ អ្នកគ្រូដឹងឬទេថា...

- ផែនដីយើងនេះ បច្ចុប្បន្នគេច្រើនហៅថា "ភពពណ៌ខៀវ" ពីព្រោះមើលពីអវកាសមកផែនដី ដែលមានផ្ទៃគ្រប ដណ្តប់ដោយសមុទ្រ និង មហាសមុទ្រអស់បីភាគបួននោះ មានពណ៌ខៀវស្ទើរតែទាំងអស់ ។
- ផ្ទៃសមុទ្រ និង មហាសមុទ្រទាំងអស់ នៅលើផែនដី សរុបមាន ៣១៦ លានគីឡូម៉ែត្រការ៉េ (៣៦១ ០០០ ០០០គ.ម$^{២}$) ។
- ក្នុងចំណោមពណ៌ទាំងឡាយនៃកាំរស្មីព្រះអាទិត្យ មានតែពណ៌ខៀវទេ ដែលអាចចូលបានជ្រៅជាងគេទៅក្នុង ទឹកសមុទ្រ ធ្វើអោយសមុទ្រមានពណ៌ខៀវ ហើយកន្លែងណាកាន់តែជ្រៅ ពណ៌ខៀវកាន់តែខ្លាំងឡើងក្រមៅ ។
- ក្នុងមួយឆ្នាំៗ ទឹកសមុទ្រ និង មហាសមុទ្រនានាបានហួតឡើងចំនួន ៣៨០ ០០០ គ.ម$^{៣}$(*) ។ ប៉ុន្តែទឹកទាំងនោះ ធ្លាក់មកលើផ្ទៃដីបានតែមួយភាគបួនប៉ុណ្ណោះ ក្រៅពីនោះធ្លាក់ចូលសមុទ្រវិញដដែល ។
- នៅក្នុងទឹកសមុទ្រចំនួន មួយពាន់លានតោន (១ ០០០ ០០០ ០០០ត) មាន ÷
  - មាស ៥ គ.ក
  - ប្រាក់ ២៥០ គ.ក
  - កូបាល់ ៥០០ គ.ក
  - ទីតាន ១ ០០០ គ.ក
  - នីកែល ២ ០០០ គ.ក
  - អ៊ុយ៉ារ៉ានីយ៉ូម ទង់ដែង និង សំណប៉ាហាំង ៣ ០០០ គ.ក

---

* ១ គីឡូម៉ែត្រគូប គឺទំហំគូបមួយដែលមានជ្រុងមួយគីឡូម៉ែត្រ ស្មើនឹងមួយពាន់លានម៉ែត្រគូប (១ ០០០ ០០០ ០០០ម$^{៣}$)

# វិញ្ញាសាប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

## សម័យប្រឡង : ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៣

**វិញ្ញាសា : វប្បធម៌ទូទៅ** (វិញ្ញាសារួម) រយៈពេល ២ ម៉ោង

ប្រធាន:

ការអភិវឌ្ឍប្រទេសជាតិអោយរីកចំរើន ប្រកបដោយសុខសុវត្ថិភាពមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលធនធានមនុស្សបានឡើយ ។ ក្នុងស្ថានភាពបច្ចុប្បន្ន តើត្រូវបណ្តុះបណ្តាលធនធានមនុស្សអោយមានលក្ខណៈសម្បត្តិដូចម្តេច? (ដប់ពិន្ទុ)

---

**វិញ្ញាសា : សីលធម៌-ពលរដ្ឋវិជ្ជា** រយៈពេល ២ ម៉ោង

ប្រធាន:

១- តើព្រះសង្ឃខ្មែរមានតួនាទីអ្វីខ្លះនៅក្នុងសង្គម ? (មួយពិន្ទុ)

២- ប្រទេសអនុវត្តរបបប្រជាធិបតេយ្យ មានអំណាចអ្វីខ្លះ ? (កន្លះពិន្ទុ)
តើអំណាចទាំងនោះ មានទំនាក់ទំនងគ្នាដូចម្តេចខ្លះ ? (កន្លះពិន្ទុ)

៣- ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងការបញ្ចេញមតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សបានចែងដូចម្តេចខ្លះ ? (បីពិន្ទុ)

៤- ប្រជារាស្ត្រខ្មែរធ្លាប់មានអរិយធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្ដុកស្ដម្ភធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ បានធ្លាក់ខ្លួនដ៏សែនវេទនាក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ ។
អ្នកជាខ្មែរមួយរូបត្រូវធ្វើដូចម្តេច ដើម្បីអោយប្រទេសឈានឡើងរីកចំរើន លូតលាស់សម្បូររុងរឿងជានិច្ចនិរន្តរ៍ ? (ប្រាំពិន្ទុ)

---

**វិញ្ញាសា : អក្សរសិល្ប៍ (ឯកទេសទី ១)** រយៈពេល ២ ម៉ោង

ប្រធាន:

លោករដ្ឋមន្ត្រី សំឡឹងមើលមុខសម ហើយពោលថា៖ "មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវមានព្រំដែន" ។

ចូរពន្យល់គំនិតខាងលើ ដោយផ្អែកលើដំណើររឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់ ។ (ដប់ពិន្ទុ)

---

**វិញ្ញាសា : អក្សរសិល្ប៍ (ឯកទេសទី ២)** រយៈពេល ២ ម៉ោង

ប្រធាន:

ផានីតបានពោលថា ÷ "កុំធ្វើជាមនុស្ស «សំបក»" ។

ចូរពន្យល់គំនិតខាងលើ ដោយផ្អែកលើដំណើររឿងចៅកែចិត្តចោរ ។ (ដប់ពិន្ទុ)

---

**វិញ្ញាសា : ជីវវិទ្យា** រយៈពេល ២ ម៉ោង

ប្រធានៈ

១- ចូរពណ៌នាដំណាក់ផ្សេងៗនៃការបង្កកំណើតរបស់មនុស្ស ។ (មួយពិន្ទុកន្លះ)

២- ក. ដូចម្តេចហៅថា សេណូទីប ? ផេណូទីប ? ចូរអោយឧទាហរណ៍បញ្ជាក់ ។

ខ. ប្រសិនបើគេចង់ដឹងសេណូទីបនៃឯកត្តៈមួយ តើត្រូវធ្វើដូចម្តេច ? (មួយពិន្ទុកន្លះ)

៣- ចូរអ្នកបកស្រាយចលនការកំណត់ភេទរបស់រុក្ខសូភីល ។ (មួយពិន្ទុកន្លះ)

៤- ក. ហេតុអ្វីបានជាអ៊ីប្រ៊ីតនៅជំនាន់ $F_1$ មានលក្ខណៈដូចគ្នាទាំងអស់ ?

ខ. ហេតុដូចម្តេចបានជាមានការផ្តាច់ចេញលក្ខណៈនៅជំនាន់ $F_2$ ?

៥- តើសម្ភារៈសេនេទិចរបស់ HIV ជា AND ឬARN? ហេតុអ្វីបានជាគេហៅ HIV ជារ៉េត្រូវីរុស? (មួយពិន្ទុកន្លះ)

៦- ច្រវាក់ទោលមួយនៃម៉ូលេគុល AND មាន $3.10^6$ នុយក្លេអូទីត ។

ក. ចូរគណនាប្រវែងម៉ូលេគុល ADN នេះ ?

ខ. កាលណាម៉ូលេគុល ADN នេះធ្វើស្វ័យដំឡើងទ្វេ តើវាត្រូវការនុយក្លេអូទីតសេរីប៉ុន្មាន ?

គ. ក្នុងម៉ូលេគុល ADN នេះ ចំនួននុយក្លេអូទីតនៃប្រភេទអាដេនីន A = ១៦% នៃចំនួនទាំងអស់ ។ ចូរគណនាចំនួននុយក្លេអូទីតនៃប្រភេទនីមួយៗរបស់ម៉ូលេគុល ។

ឃ. ម៉ូលេគុល ADN នេះអាចប្រើជាគំរូពុម្ព តើវាត្រូវការម៉ូលេគុល ARN ប៉ុន្មាន ?បើ ARN នីមួយៗជាមធ្យមមាន ១០ 000នុយក្លេអូទីត ? (ពីរពិន្ទុកន្លះ)

---

**វិញ្ញាសា : ផែនដីវិទ្យា** រយៈពេល ២ ម៉ោង

ប្រធានៈ

១- តើការគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជាត្រូវប្រព្រឹត្តទៅតាមបច្ចេកទេសបែបណាខ្លះ ? (មួយពិន្ទុ)

២- ដូចម្តេចដែលហៅថាឥន្ធនៈសំយោគ? តើគេប្រើវិធីអ្វីខ្លះ ដើម្បីផលិតឥន្ធនៈសំយោគ ? ចូរពន្យល់? (ពីរពិន្ទុ)

៣- តើយើងជាពលរដ្ឋម្នាក់ៗត្រូវធ្វើអ្វីខ្លះ ដើម្បីការពារ និង ថែរក្សាធនធានធម្មជាតិដែលមាននៅលើទឹកដីប្រទេសកម្ពុជា ? (ពីរពិន្ទុ)

៤- តើឥទ្ធិពលនៃការបំបែកថាមពលនុយក្លេអ៊ែបានផ្តល់នូវគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះ ? (ពីរពិន្ទុ)

៥- តើកំណើនផលផ្ទះកញ្ចក់បានផ្តល់នូវផលវិបាកអ្វីខ្លះដល់បរិស្ថាន និង សង្គម ? ចូរពន្យល់ ? (បីពិន្ទុ)

---

**វិញ្ញាសា : ភូមិវិទ្យា** រយៈពេល ២ ម៉ោង

ប្រធានៈ

១- តើអ្វីខ្លះជាលក្ខណៈសម្បត្តិធម្មជាតិប្រសើរនៃឈូងសមុទ្រថៃ ដែលអនុគ្រោះដល់សំណង់កំពង់ផែព្រះ សីហនុ និង សំណង់ស្ថានីយទេសចរណ៍ ? (ពីរពិន្ទុ)

២- ចរន្តទឹកទន្លេសាបមានទិសដៅពីរ ជួនកាលហូរពីត្បូងទៅជើង ជួនកាលហូរពីជើងទៅត្បូង ។ តើបាតុភូតនេះ កើតឡើងនៅរដូវណាខ្លះ ។ ចូរពន្យល់អោយបានច្បាស់លាស់ ? (ពីរពិន្ទុ)

៣- បាតុភូតភ្លៀងកក់ខែ កួនរដូវប្រាំង និង រដូវក្ដៅហួតហែងកើតមាននៅពេលណាខ្លះ ? តើបាតុភូតទាំងនោះ បង្កភាពអន្តរាយអ្វីខ្លះចំពោះកសិកម្ម ? (ពីរពិន្ទុ)

៤- ដើម្បីទាក់ទាញភ្ញៀវទេសចរអោយបានចំនួនច្រើន យើងត្រូវរៀបចំប្រទេសជាតិយ៉ាងដូចម្ដេច? (ពីរពិន្ទុ)

៥- តើចំណុចខ្លាំង និង ចំណុចខ្សោយនៃកសិកម្មអាមេរិចមានអ្វីខ្លះ ? (ពីរពិន្ទុ)

---

**<u>វិញ្ញាសា</u> : ប្រវត្តិវិទ្យា** រយៈពេល ២ ម៉ោង

<u>ប្រធាន:</u>

១- តើមានព្រះរាជាប៉ុន្មានអង្គដែលបានសោយរាជ្យនៅសម័យអង្គរ ? ព្រះនាមអ្វីខ្លះ ? ព្រះរាជាអង្គណាខ្លះដែល លេចធ្លោជាងគេនៅសម័យនោះ ? មានព្រះនាមអ្វីខ្លះ ? តើលេចធ្លោដោយសារអ្វី ?(ពីរពិន្ទុកន្លះ)

២- ក្រោយសង្គ្រាមលោកលើកទី ២ តើប្រជាជនសូវៀតកសាងប្រទេសបានលទ្ធផលដូចកាលពីមុនសង្គ្រាមដែរ ឬទេ ? ព្រោះអ្វី ? (ពីរពិន្ទុកន្លះ)

៣- តើអគ្គលេខាធិការអង្គការសហប្រជាជាតិមានប៉ុន្មាននាក់រហូតដល់សព្វថ្ងៃនេះ ? មានឈ្មោះអ្វីខ្លះ ? ជនជាតិ អ្វី ? គ្រប់គ្រងពីឆ្នាំណាដល់ឆ្នាំណា ? ហើយមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះដែលកើតមានឡើងនៅអាណត្តិ ចុងក្រោយនេះ ? (ពីរពិន្ទុកន្លះ)

៤- តើប្រទេសភីលីពីនធ្លាប់ស្ថិតនៅក្រោមនឹមអាណានិគមនិយមណាខ្លះ ? តើបែបផែនអាណានិគមណាមួយ ដែលធ្វើអោយមានការរីកចំរើនដល់ម្ចាស់ស្រុកជាងគេ ? (ពីរពិន្ទុកន្លះ)

---

**<u>វិញ្ញាសា</u> : គីមីវិទ្យា** រយៈពេល ២ ម៉ោង

<u>ប្រធាន:</u>

១- ចូររៀបរាប់ពីបំលែងថាមពលក្នុងអគ្គីសនីវិភាគ ? (មួយពិន្ទុ)

២- ប្រភេទខាងក្រោមអាចចាត់ទុកជាអាស៊ីតផង និង បាសផងក្នុងគូពីរផ្សេងពីគ្នា គឺ $HSO_4^-$, $HS^-$, $H_2O$ និង $HSO_3^-$ ។

ក. តើគេចាត់ទុកវាចូលក្នុងប្រភេទអ្វី ? បើវាដើរតួជាអាស៊ីតផង និង បាសផង ។

ខ. ចូរសរសេរគូទាំងពីររបស់ប្រភេទទាំងអស់ខាងលើនោះ ?

គ. ចូរបញ្ជាក់ថា គូណាជាអាស៊ីតខ្លាំង ហើយគូណាជាបាសខ្លាំង ? (ពីរពិន្ទុកន្លះ)

៣- ក. ចូរសរសេររូបមន្តស្ទើរលាតនៃអ៊ីសូមែរប្លង់ផ្សេងៗដែលត្រូវនឹងរូបមន្តដុល $C_4H_{10}O$ ។

ខ. ចូរបញ្ជាក់ពីប្រភេទអ៊ីសូមែនីមួយៗធៀបនឹងប៊ុយតាន -1- អុល ?

គ. អ៊ីសូមែមួយក្នុងចំណោមអ៊ីសូមែទាំងអស់អាចបង្ហាញក្រោមសណ្ឋានជា អ៊ីសូមែរំលោពីរដែលអាចញែកចេញពីគ្នាបាន ។ តើអ៊ីសូមែមួយណា ? ព្រោះអ្វី ? ( ពីរពិន្ទុកន្លះ )

៤- គេរៀបចំសូលុយស្យុង A នៃអាស៊ីតអេតាណូអ៊ិច កំហាប់ $10^{-1}mol\ L^{-1}$ ។ គេយក 500ml នៃសូលុយស្យុងA ទៅបំពេញដោយទឹកសុទ្ធអោយបានមាឌ 1000ml នោះយើងទទួលបានសូលុយស្យុង B ។ គេយក 100ml នៃសូលុយស្យុង A ហើយបំពេញដោយទឹកបិទអោយបានមាឌ 1000ml នោះគេទទួលបានសូលុយស្យុង C ។

ក. គណនាកំហាប់ $C_C$ និង $C_B$ របស់សូលុយស្យុង C និង B ?

ខ. ចូរតំរៀប $P^H$ នៃសូលុយស្យុង A,B និង C តាមលំដាប់កើនឡើង ?

គ. គណនាកំហាប់នៃប្រភេទគីមីផ្សេងៗក្នុងសូលុយស្យុង B ? បើគេដឹងថា $P^H{}_B = 3,1$ ។

ឃ. គណនាភាគរយនៃ $CH_3COOH$ ដែលបំបែកជាអ៊ីយ៉ុងក្នុងសូលុយស្យុង B ?

ចូរប្រៀបធៀបភាគរយបំបែកអ៊ីយ៉ុងនៃ$CH_3COOH$ ក្នុងសូលុយស្យុង A និងសូលុយស្យុងC ។ ( បួនពិន្ទុ )

---

**វិញ្ញាសា : រូបវិទ្យា (ឯកទេសទី ១)** រយៈពេល ២ ម៉ោង

**ប្រធាន:**

១- តើច្បាប់ទំនាញសកលសិក្សាអំពីអ្វី ? ចូរសរសេររូបមន្តបញ្ជាក់ ។ ( មួយពិន្ទុ )

២- តើខ្សែដែនអគ្គិសនីឯកសណ្ឋានក្នុងមជ្ឈដ្ឋានមួយមានលក្ខណៈសំគាល់ដូចម្តេច ? ( កន្លះពិន្ទុ )

៣- ចំណុចបន្ទុកអគ្គិសនីពីរមានតំលៃ $q_1 = 10^{-8}c$ និង $q_2 = 10^{-9}c$ ស្ថិតនៅចំងាយពីគ្នា 3cm ។ ចូរគូសតាងកំលាំងដែលបន្ទុកនីមួយៗមានអំពើលើគ្នា និង គណនាអាំងតង់ស៊ីតេនៃកំលាំងនោះ ។ ( មួយពិន្ទុកន្លះ )

៤- គេអោយកុងដង់សាទ័រមួយចំនួនដែលមានកាប៉ាស៊ីតេដូចគ្នាគឺ 3μF ។ តើគេត្រូវប្រើកុងដង់សាទ័រយ៉ាងតិចប៉ុន្មាន និង ផ្គុំយ៉ាងដូចម្តេច ដើម្បីអោយកាប៉ាស៊ីតេសមមូលរបស់បង្គុំស្មើនឹង 5μF ? ( បីពិន្ទុ )

៥- ជនិតាអគ្គិសនីមួយមានកំលាំងអគ្គិសនីចលករ E = 100v និង រេស៊ីស្តង់ក្នុង r = 2Ω ។ គេភ្ជាប់វាទៅនឹងសៀគ្វីក្រៅដែលមានរេស៊ីស្តង់ R = 3Ω ។ រេស៊ីស្តង់នោះតជាស៊េរីជាមួយកង្ហារមួយដែលមានកំលាំងច្រាសអគ្គិសនីចលករ e = 70v និង រេស៊ីស្តង់ក្នុង r' = 1 Ω ។ ចូរគណនា :

ក. អាំងតង់ស៊ីតេចរន្ត I

ខ. ផលសងប៉ូតង់ស្យែលនៃគ្រឿងទទួល

គ. អានុភាពអគ្គិសនីដែលគ្រឿងទទួលបានទទួល

ឃ. អានុភាពបានការដែលគ្រឿងទទួលបានបំលែង ។ ( បួនពិន្ទុ )

---

**វិញ្ញាសា : រូបវិទ្យា (ឯកទេសទី ២)** រយៈពេល ២ ម៉ោង

**ប្រធាន:**

១- ដូចម្តេចដែលហៅថា ដែនម៉ាញេទិចឯកសណ្ឋាន ? ( មួយពិន្ទុ )

២- ដូចម្តេចដែលហៅថា កំលាំងអេឡិចត្រូម៉ាញេទិច ? ( មួយពិន្ទុ )

៣- ក្នុងបង្គុំកុងដង់សាទ័រ តើវិធីផ្គុំណាបង្កើនកាប៉ាស៊ីតេ ហើយវិធីផ្គុំណាបង្កើនផលសងប៉ូតង់ស្យែល ? ( ពីរពិន្ទុ )

៤- គេអោយបង្គុំកុងដង់សាទ័រដូចរូបខាងក្រោម ÷




$C_1 = C_2 = C_3 = 4\mu F, C_4 = 6\mu F$

ចូរគណនាកាប៉ាស៊ីតេសមមូលនៃបង្គុំ ។ ( បីពិន្ទុ)

៥- គេមានជនិតាអគ្គិសនីពីរដូចគ្នា ដែលជនិតានីមួយៗមានកំលាំងអគ្គិសនីចលករ $E_1$ និង រេស៊ីស្តង់ $r_1$ ។ ពេលជនិតាទាំងពីរផ្គុំជាសេរី ហើយតភ្ជាប់ទៅរេស៊ីស្តង់ក្រៅ $R = 2\Omega$ នោះវាបញ្ចេញចរន្ត $I_1 = 0,75A$ ។ បើជនិតាខាងលើនេះផ្គុំជាខ្នែងវិញ ហើយតភ្ជាប់ទៅ R ដដែល នោះវាបញ្ចេញចរន្ត $I_2 = 0,6A$ ។ គណនាកំលាំងអគ្គិសនី $E_1$ និង រេស៊ីស្តង់ក្នុង $r_1$ ? ( បីពិន្ទុ)

---

**វិញ្ញាសា : គណិតវិទ្យា** រយៈពេល ២ ម៉ោង

**ប្រធាន:**

១- ក. សរសេរចំនួនកុំផ្លិច ជាទំរង់ត្រីកោណមាត្រ $1 + i\sqrt{3}$

ខ. ដោះស្រាយ $|z| - z = 1 + 2i$ , (z ចំនួនកុំផ្លិច) ។ ( មួយពិន្ទុកន្លះ)

២- ក. គណនាដេរីវេទី 5 នៃអនុគមន៍ $f(x) = x^2 + 2x^4 + 3x^3 - 2$

ខ. កំណត់ដេរីវេទី n នៃអនុគមន៍ $h(x) = x^n$ , $(n \in N^*)$ ។ ( មួយពិន្ទុកន្លះ)

៣- រកព្រីមីទីវ F(x) នៃអនុគមន៍ f(x)= cosx ដែលខ្សែកោងតាង F(x) កាត់តាមចំណុច $A(\frac{\pi}{2},0)$ ។

( មួយពិន្ទុកន្លះ)

៤- រកចំលើយនៃសមីការឌីផេរ៉ង់ស្យែល ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលអោយ $y'' - 3y' + 2y = 0$

$y(1) = 1 , y'(1) = 3$ ។ ( មួយពិន្ទុ)

៥- ក្នុងតំរុយអរតូណរមាល់ $(0, \vec{i}, \vec{j}, \vec{k})$ គេអោយប្លង់ពីរ (α) និង(β) មានសមីការរៀងគ្នា

$3x - 2y + 2z - 5 = 0$ និង $4x + 5y - x + 1 = 0$

ក. ស្រាយបញ្ជាក់ថា ប្លង់ (α) អរតូកូណាល់ប្លង់ (β)

ខ. សរសេរសមីការប៉ារ៉ាម៉ែត បន្ទាត់ប្រសព្វនៃប្លង់ (α) នឹង (β) ។ ( ពីរពិន្ទុ)

៦- គេអោយអនុគមន៍ $f(x) = \dfrac{ax^2 + bx}{x^2 - 4x + 3}$

ក. រកតម្លៃ a និង b ដោយដឹងថា អនុគមន៍មានតម្លៃអប្បបរមាស្មើនឹង 4 ត្រង់ x = 2

ខ. សិក្សាទិសដៅអថេរភាព និង សង់ក្រាបនៃអនុគមន៍ f(x) ចំពោះតម្លៃ a និង b ដែលរកឃើញ ។

( ពីរពិន្ទុកន្លះ)

# សកម្មភាពក្នុងជីវភាពនយោបាយ និង ជីវភាពសាធារណៈ

យើងដឹងហើយថា តាមប្រវត្តិសាស្ត្រខ្មែរចំនួនស្ត្រីខ្មែរបានចូលរួមតិចតួចណាស់ ក្នុងមុខតំណែងដឹកនាំផ្នែកនយោបាយ និង មុខដំណែងដឹកនាំសហគមន៍ ។ តើបច្ចុប្បន្នមានការប្រែប្រួល យ៉ាងណាចំពោះបញ្ហានេះ ?

## ១~ សិទ្ធិស្មើភាពគ្នាក្នុងការបោះឆ្នោត និង ការឈរឈ្មោះអោយគេបោះឆ្នោត



យោងតាមរដ្ឋធម្មនុញ្ញ ស្ត្រីមានសិទ្ធិបោះឆ្នោត និង អាចមានសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ។ ការពិតបង្ហាញច្បាស់នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ ដែលមានស្ត្រីជាង ៥០% បានបំពេញភារកិច្ចជាអ្នកបោះឆ្នោត ។ ប៉ុន្តែមានស្ត្រីតែ ២០% ដែលបានទទួលឋានៈ តួនាទី ហើយនៅក្នុងចំណោមសមាជិករដ្ឋសភាមានស្ត្រីតែ ១១.៥២% ប៉ុណ្ណោះ ។ ជាមធ្យមនារីថ្នាក់ដឹកនាំមូលដ្ឋាន ថ្នាក់កណ្ដាល និង ថ្នាក់ក្រោមៗមានប្រមាណ ១០% ។ ក្នុងចំណោមគណបក្សនយោបាយទាំង ៣៩ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ មាននារី ៥ រូបជាប្រធានគណបក្ស ហើយនៅឆ្នាំ ២០០៣មានគណបក្សចំនួន ២៣ មានស្ត្រីជាប្រធានគណបក្ស ១ រូបតែប៉ុណ្ណោះ ។

នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ ឆ្នាំ ២០០២ ថ្វីត្បិតតែពុំទាន់ឯកភាពស្មើគ្នាលើការដាក់ចេញនូវកូតាស្ត្រីជាវិធានច្បាប់ក្ដី ក៏គណបក្សដែលជាប់ឆ្នោតបានជំរុញស្ត្រីអោយឈរឈ្មោះជាបេក្ខនារីក្រុមប្រឹក្សាឃុំ-សង្កាត់ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្នុងចំណោមបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ៧៥.២៨៧ នាក់ មានបេក្ខនារីចំនួន ១២.៣៧៥ នាក់ ត្រូវជា ១៦% ។

ក្នុងចំណោមបេក្ខនារីទាំងអស់ មានបេក្ខនារី ៩៧៧នាក់ (៨.១៧%) ត្រូវបានជាប់ឆ្នោត ហើយត្រូវធ្វើការនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងចំណោមឃុំ-សង្កាត់ចំនួន ១៦២១ នៅទូទាំងប្រទេស ។

យោងតាមអនុក្រឹត្យលេខ ២២ អនក្របក ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ ចុះថ្ងៃទី ២៥ មីនា ២០០២ (មាត្រា ១៩) ចែងថា "ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ម្នាក់ជានារី ដើម្បីអោយទទួលបន្ទុកកិច្ចការនារី និង កុមារ ។ ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវតែងតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារ ត្រូវបានផ្ដល់សិទ្ធិអោយចូលរួមក្នុងរាល់កិច្ចពិភាក្សា ឬកិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ឃុំ-សង្កាត់ និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

បទពិសោធដំបូងក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ត្រូវបានចាត់ទុកថា ទទួលបានជោគជ័យក្នុងការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការងារអភិបាលកិច្ចល្អ និង ជាពិសេសក្នុងការបង្កើតការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្ដីសំរេចចិត្ត ។ ទោះបីជាពីមុនការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្ដីសំរេចចិត្តនៅក្នុងផ្នែកសាធារណៈមានចំនួនតិចតួចក៏ដោយ ក៏វត្តមានរបស់ស្ត្រីក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានកើនឡើង ២៦% ។ នៅឆ្នាំ ១៩៩៧ ហើយបានឈានដល់កំរិតមធ្យមគឺ ៤០% នៅឆ្នាំ ១៩៩៨ ជាលទ្ធផលមានភស្តុតាងពីអង្គការមិនមែនរដ្ឋាភិបាល និង ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន បញ្ជាក់ថា ការជ្រើសរើស និង ការរៀបចំគំរោង មានការឆ្លើយតបកាន់តែច្រើនឡើងទៅនឹងតំរូវការរបស់ស្ត្រី (ទិន្នន័យរបស់ធនាគារពិភពលោកឆ្នាំ ២០០៣) ។

## ២. តើសិទ្ធិស្មើភាពគ្នាក្នុងការចូលរួមក្នុងជីវភាពនយោបាយ និង ជីវភាពសាធារណៈមានការរីកចំរើនដូចម្ដេចដែរ ?

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ផ្ដល់ដល់ស្ត្រីនូវសិទ្ធិស្មើភាពគ្នាជាមួយនឹងបុរសក្នុងការចូលរួមក្នុងអង្គការមិនមែនរដ្ឋាភិបាល និង សមាគមផ្សេងទៀត ក្នុងជីវភាពនយោបាយ និង ជីវភាពសាធារណៈ ។ បច្ចុប្បន្នអង្គការមិនមែនរដ្ឋាភិបាល និង សមាគមជាច្រើនបានផ្ដោតទៅលើការអភិវឌ្ឍសិទ្ធិមនុស្ស សុខភាពស្ត្រី ការពន្យាកំណើត ការគាំពារមាតា និង ទារក ។ល។ និង សកម្មភាពផ្សេងទៀត ដូចជាការស្រាវជ្រាវឯកសារ ការផលិត និង ការបោះពុម្ពផ្សាយ ការផ្ដល់ឥណទានខ្នាតតូច ការផ្ដល់ទីជំរក ការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធដូចជា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង ការកសាងសមត្ថភាពផ្នែកសិទ្ធិមនុស្ស និង ច្បាប់ ។ ការសង្កេតបានបង្ហាញថា ស្ត្រីជាច្រើនបានចូលរួមយ៉ាងសកម្មក្នុងអង្គការមិនមែនរដ្ឋាភិបាល ហើយក្នុងនោះស្ត្រីមួយចំនួនធំមានតួនាទីជាអ្នកសំរេចលើកិច្ចការនានា ចំពោះបញ្ហាធំៗខាងលើ ។

**៣-  តើមានវិធានការអ្វីខ្លះ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងជីវភាពនយោបាយ និង សាធារណៈ?**

រាជរដ្ឋាភិបាល និង គណបក្សនយោបាយមួយចំនួនបាននិងកំពុងខំប្រឹងប្រែងជំរុញអោយស្ត្រីចូលរួមកាន់តែច្រើនក្នុងជីវភាពនយោបាយ និង សាធារណៈ ។ រាជរដ្ឋាភិបាល បានបង្កើតអោយមានអន្តរាគមន៍ជាយុទ្ធសាស្ត្រមួយចំនួនដូចជា ផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ (២០០១-២០០៥) ផែនការនារីរតនៈ និង ផែនការជាតិកាត់បន្ថយភាពក្រីក្រ ដើម្បីកសាងសមត្ថភាពរបស់ស្ត្រី ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលមានគោលបំណងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី តាមរយៈការបណ្ដុះបណ្ដាលអំពីយេនឌ័រ និង ការអភិវឌ្ឍ និង ផ្ដល់ការបណ្ដុះបណ្ដាលដល់មេដឹកនាំសហគមន៍មូលដ្ឋានដូចជា ក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម ។

**ឃួរ ស៊ីរី**

❀❀❀❀❀❀❀

**អត្ថន័យនៃការអប់រំ ក្នុងសេចក្ដីព្រាងច្បាប់អប់រំ**

ការអប់រំ ក្នុងច្បាប់នេះមានន័យថា ជាដំណើរការសិក្សាដើម្បីការអភិវឌ្ឍន៍ខាងបុគ្គលិកលក្ខណៈ ចិត្តសម្បទា ប្រាជ្ញាសម្បទា និង កាយសម្បទា តាមរយៈរាល់សកម្មភាពដែលធ្វើអោយអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញសមត្ថភាព បំណិនជីវិត បំណិនការងារ រួមទាំងការបញ្ចេញទស្សនៈផ្ទាល់ខ្លួន និង ទស្សនៈសិក្សា ប្រកបដោយសេចក្ដីថ្លៃថ្នូរ និង គុណធម៌ ។

# ស្ត្រីខ្មែរនៅដើមសតវត្សទី២០




តន្ត្រីការិនី




នាដ្យការីវ័យក្មេង